ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


០៣-៣-២០០០ -ព្រះរាជក្រម ជស/រកម/០៣០០/១០ ច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ៤២១


### ២-ព្រះរាជក្រឹត្យ


០៣-៣-២០០០ -ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៦ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៤៣១

០៦-៣-២០០០ -ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៧ តែងតាំងឯកឧត្តម ខៀ កុសលៈ ជាទីប្រឹក្សាក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ៤៣៨

០៦-៣-២០០០ -ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៨ តែងតាំងឯកឧត្តម ហុង ឡុង ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ៤៣៩


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


០៣-៣-២០០០ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្ដីពីវិសោធនកម្ម នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រង់មាត្រា ១-២-៣ និង ៨ ពាក់ព័ន្ធទៅនឹងឯកសណ្ឋានកងប៉ូលីសជើងគោក កងនាវាចរ កងអាកាស ចរ ឯកសណ្ឋានព្រៃទ័ព និងកងកិត្តិយស ៤៤០

០១-៣-២០០០ -អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៤៥០

០១-៣-២០០០ -អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្ដីពីការបំពាក់ឋានន្តរសក្តិនាយនគរបាលជាតិ ៤៥១

០២-៣-២០០០ -អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្ដីពីការបញ្ជូនមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌដើមវិញ ៤៥១

០៧-៣-២០០០ -អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៤៥២

០៧-៣-២០០០ -អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៥៣

## ២-សារាចរ

០៣-៣-២០០០ -សារាចរ លេខ ០១ ស.រ ស្តីពីការរៀបចំកសាងផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គមកិច្ច ៥ ឆ្នាំ លើកទី ២ ( ២០០១ ២០០៥ ) ៥៦១

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

#### ប្រកាស

០៧-៣-២០០០ -ប្រកាសលេខ ៥៥០ អយក.ប្រក. ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ " ភ្នំប្រុស " ទៅជាវិទ្យាល័យ " សម្តេច ជួន ណាត " ស្ថិតនៅក្នុងឃុំក្រឡា ស្រុកកំពង់សៀម ខេត្ត កំពង់ចាម ៥៦៦

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

#### ប្រកាស

០៧-៣-២០០០ -ប្រកាសលេខ ៤៩ កធស .ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៦៧

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រម ជស/រកម/០៣០០/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១-១២-១៣-១៨-២២-២៥-២៦-២៨-៣០-៣៤-៥១-៩០-៩១-៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាសអោយប្រើ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៣ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែ មករា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី២

នីតិកាលទី១ និងដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា៤០ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ច្បាប់នេះជាច្បាប់រៀបចំអង្គការដែលមានគោលបំណងបង្កើតនូវអាជ្ញាធរសវនកម្មជាតិមួយដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ ។ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចចំពោះការអនុវត្តន៍មុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ។ អគ្គសវនករត្រូវបានប្រគល់អំណាចជូនក្នុងការបំពេញសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការនិងកម្មវិធីរបស់បណ្តាស្ថាប័នគ្រប់គ្រងដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាល។

ច្បាប់នេះក៏បានបង្កើតនូវមុខងារសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន និងបណ្តាសហគ្រាសសាធារណៈផងដែរ ។

**មាត្រា ២ .-**

បណ្តាស្ថាប័នគ្រប់គ្រងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ រួមមានបណ្តាក្រសួង ស្ថាប័នភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋនិងស្ថាប័នហិរញ្ញវត្ថុរដ្ឋចំរុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើមុនផ្កាប់ និងឥណទានរួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសប្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញនិងសហគ្រាសវិនិយោគឯកជនផង ។

**មាត្រា ៣ .-**

ក្នុងច្បាប់នេះ សវនកម្មផ្ទៃក្រៅរាប់បញ្ចូលនូវការអនុវត្តន៍ប្រភេទសវនកម្មដូចតទៅ :

ក-សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ។

ខ-សវនកម្មលើការគ្រប់គ្រងកម្មវិធីគំរោងឥណទានដែលបានទទួលពីមូលនិធិក្រៅប្រទេស ។

គ-សវនកម្មលើប្រព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តិទៅលើបណ្តាស្ថាប័ន ។

ឃ-សវនកម្មលើការវាយតំលៃ ការផ្តល់លទ្ធផលល្អ និងប្រសិទ្ធភាពក្នុងការអនុវត្តន៍ ។

ង-សវនកម្មលើអង្គការដែលមិនរកប្រាក់ចំណេញ សមាគម គណបក្សនយោបាយនិងសវនកម្មលើសហគ្រាសវិនិយោគឯកជន ដូចមានចែងក្នុងមាត្រា ២ នៃច្បាប់នេះ ។

ច-សវនកម្មតាមសំណើពិសេស ។

មាត្រា ៤ ._

សវនកម្មផ្ទៃក្រៅ គឺជាការពិនិត្យពិចារណា ឬការពិនិត្យឡើងវិញលើកិច្ចបញ្ជីកាគណនេយ្យ ប្រព័ន្ធគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការត្រួតពិនិត្យស្ថាប័នគ្រប់គ្រងដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ និងតាមស្តង់ដារនៃការធ្វើសវនកម្មរបស់រាជរដ្ឋាភិបាល ដើម្បីផ្តល់ការធានាថា :

ក-បណ្តាសកម្មភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈសេចក្តីថ្លែងការណ៍ និងតាមរបាយការណ៍ ។

ខ-បណ្តាសកម្មភាពទាំងនេះត្រូវបានអនុវត្តដោយអនុលោមតាមគោលការណ៍គណនេយ្យទូទៅ ។

គ-ការត្រួតពិនិត្យនីតិវិធីនិងការអនុវត្តន៍ដោយអនុលោមតាមច្បាប់ បទបញ្ជា កិច្ចព្រមព្រៀងប្រព័ន្ធគ្រប់គ្រង កិច្ចសន្យា កម្មវិធីនិងលក្ខណៈវិនិច្ឆ័យផ្សេងទៀត ដែលទាក់ទងដល់ចំណូល ចំណាយ និងការប្រើប្រាស់ប្រភពធនធានរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ២
## ប្រភេទសវនកម្ម

មាត្រា ៥ ._

សវនកម្មលើសេចក្តីថ្លែងការណ៍និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នដែលជាមូលដ្ឋានសំរាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល នៅដំណាច់ឆ្នាំនៃការិយបរិច្ឆេទដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនពេលដាក់ជូនទៅអង្គការនីតិបញ្ញត្តិ ។

សវនកម្មលើភាពត្រឹមត្រូវ ភាពពិតប្រាកដ ការយល់ព្រម ការធ្វើឲ្យមានសុពលភាព និងស្របតាមទិន្នន័យហិរញ្ញវត្ថុ ដូចមានបង្ហាញលើរបាយការណ៍របស់បណ្តាក្រសួងស្ថាប័ន និងរបាយការណ៍ហិរញ្ញវត្ថុសរុបរបស់រាជរដ្ឋាភិបាល ។

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ អាជ្ញាធរ រួមមានតារាងតុល្យការ របាយការណ៍អំពីប្រាក់ចំណេញ ការខាតបង់ និងការវិភាគគណនីដែលជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។ សវនកម្មនេះ ក៏ត្រូវរាប់បញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសអាជីវកម្មនៅក្នុងបណ្តាក្រសួងស្ថាប័ន ខេត្ត ក្រុង និងរដ្ឋបាលមូលដ្ឋានផងដែរ ។

មាត្រា ៦ ._

សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងៗទៀតដែលសំណូមពរដោយបណ្តាភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និងបណ្តាឥណទាយកនៅក្នុងគំរោងផ្តល់មូលនិធិពីក្រៅប្រទេស ។ សវនកម្មនេះ ត្រូវបញ្ជាក់អំពីភាពសមស្របនឹងភាពត្រឹមត្រូវនៃឯកសារយុត្តការណ៍ក្នុងការដកប្រាក់ និងការចំណាយលើគំរោងនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវកំណត់ហេតុបង្ហាញនូវការសមស្របទៅនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាននិងកិច្ចព្រមព្រៀងគំរោង ។ សវនកម្មនឹងបន្តបន្ថែមទៅទៀត លើការវាយតំលៃចំពោះការសំរេចគោលដៅ នៅពេលចប់គំរោងទាំងនោះ ។

មាត្រា ៧ ._

សវនកម្មលើប្រព័ន្ធពិនិត្យនានាដើម្បីរៀបចំនូវមតិលើភាពសមស្របគ្រប់ជ្រុងជ្រោយ ក្នុងការចាត់ចែងប្រព័ន្ធគ្រប់គ្រងនិងការប្រព្រឹត្តិទៅ ដែលបានបង្កើតឡើងដោយស្ថាប័នគ្រប់គ្រងលើសកម្មភាពនិងកិច្ចប្រតិបត្តិការទាំងឡាយ ។

មាត្រា ៨ ._

សវនកម្មលើមុខងារ ឬកិច្ចការកំពុងអនុវត្តរវាងស្ថាប័នគ្រប់គ្រង និងស្ថាប័នគ្រប់គ្រងដើម្បីធានាសកម្មភាពកិច្ចប្រតិបត្តិការដែលទាក់ទងដល់មុខងារ នៅក្នុងបណ្តាស្ថាប័នគ្រប់គ្រងឲ្យអនុវត្តគោរពតាមច្បាប់ អនុបញ្ញត្តិនិង គោលការណ៍ទាំងឡាយកំពុងអនុវត្ត ។ សវនកម្មនេះ រាប់បញ្ចូលទាំងលទ្ធកម្មសាធារណៈ ជម្រើសមុគ្គលិក កិច្ចសន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងបេសកកម្ម ។

មាត្រា ៩ ._

សវនកម្មដើម្បីរាយការណ៍អំពីការសន្សំសំចៃ ការផ្តល់ឲ្យនូវផលល្អ ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលទ្ធផលនៃកម្មវិធីរបស់រាជរដ្ឋាភិបាល ។ សវនកម្មនេះ រាប់បញ្ចូលទាំងការពិនិត្យពិចារណាឡើងវិញនៃកិច្ចប្រតិបត្តិការរបស់បណ្តាស្ថាប័នសាធារណៈ ទោះជាស្ថាប័នហិរញ្ញវត្ថុ ឬមិនមែនស្ថាប័នហិរញ្ញវត្ថុក៏ដោយ ។

មាត្រា ១០ ._

សវនកម្មលើការអនុវត្តន៍ស្របតាមបទប្បញ្ញត្តិជាធរមាន ក្នុងកិច្ចប្រតិបត្តិការរបស់អង្គការដែលមិនរកប្រាក់ចំណេញ សមាគមនិងគណបក្សនយោបាយដែលបានទទួលជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលក្នុងទម្រង់ទ្រាយលើកលែងពន្ធគយ ពន្ធលើប្រាក់ចំណូល និងពន្ធអាករឯទៀត ព្រមទាំងបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិដែលពុំមានការអនុញ្ញាតដោយច្បាប់ ។ គោលដៅនៃសវនកម្មនេះ គឺដើម្បីកុំឲ្យរាជរដ្ឋាភិបាលត្រូវបានបាត់បង់ប្រាក់ចំណូលដែលបណ្តាលមកពីការលើកលែងពន្ធ និងដើម្បីធានាថាស្ថាប័នគ្រប់គ្រងបានដំណើរការទៅតាមក្របខ័ណ្ឌ នៃគោលបំណងរបស់ខ្លួន ។

មាត្រា ១១ ._

សវនកម្មលើការអនុវត្តន៍ស្របតាមបទប្បញ្ញត្តិជាធរមានរបស់សហគ្រាសវិនិយោគឯកជនដែលបានទទួលការលើកលែងពន្ធ និងសម្បទានពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើអាជីវកម្មធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សវនកម្មទាំងនេះតម្រង់ទិសទៅលើការអនុវត្តន៍ទៅតាមកិច្ចព្រមព្រៀង និងបណ្តាលក្ខខណ្ឌនៃការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

មាត្រា ១២ ._

សវនកម្មតាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុនិងធនាគារនៃរដ្ឋសភា ឬរដ្ឋសភា ឬព្រឹទ្ធសភា ឬក្រសួង ឬស្ថាប័ននានា ឬអាជ្ញាធរសំរាប់ធ្វើការត្រួតពិនិត្យពិសេសឡើងវិញលើវិស័យមួយផ្នែក ឬទាំងអស់នៃកិច្ចប្រតិបត្តិការរបស់ម្ចាស់សំណើ ។ ការអនុវត្តន៍នៃសវនកម្មដែលមានចែងក្នុងមាត្រានេះ គឺស្ថិតនៅលើឆន្ទានុសិទ្ធិរបស់អគ្គសវនករ ។

មាត្រា ១៣ ._

សវនកម្មដែលមានចែងពីមាត្រា ៥ ដល់មាត្រា១២ ត្រូវធ្វើដោយអាជ្ញាធរសវនកម្មជាតិ ។

ជំពូកទី ៣

**អាជ្ញាធរសវនកម្មជាតិ**

មាត្រា ១៤ ._

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យ ហើយត្រូវធ្វើរបាយការណ៍នៃសវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាលដើម្បីជ្រាបជាពត៌មាន ។ អាជ្ញាធរសវនកម្មជាតិដឹកនាំដោយដោយអគ្គសវនករមួយរូបនិងមានអគ្គសវនកររង២ (ពីរ ) រូប ។

មាត្រា ១៥ ._

ក្នុងការបំពេញបេសកកម្មរបស់ខ្លួន និងដើម្បីអនុវត្តច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានសិទ្ធិអំណាចចេញសេចក្តីសំរេច បទបញ្ជា សារាចរ និងការណែនាំផ្សេងៗទៀត ។

មាត្រា ១៦ ._

មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិមានលក្ខន្តិកៈដោយឡែក ។

មាត្រា ១៧ ._

អាជ្ញាធរសវនកម្មជាតិមានថវិកាដោយឡែករបស់ខ្លួនផ្តល់ដោយថវិកាជាតិ ។ ការគ្រប់គ្រងចំណូលនិងចំណាយនៃអាជ្ញាធរសវនកម្មជាតិ ត្រូវស្ថិតនៅក្រោមច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។

ជំពូកទី ៤

**ការតែងតាំងអគ្គសវនករ និងអគ្គសវនកររង**

មាត្រា ១៨ ._

អគ្គសវនករ និងអគ្គសវនកររង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល និងដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋសភាតាមសំលេងភាគច្រើន ២/៣ ( ពីរភាគបី ) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

អគ្គសវនករនិងអគ្គសវនកររង នឹងត្រូវបានទទួលការតែងតាំងសំរាប់អាណត្តិ ៥ ( ប្រាំ ) ឆ្នាំ ហើយអាចទទួលការតែងតាំងតែមួយដងទៀតប៉ុណ្ណោះ នៅពេលចប់អាណត្តិទី១ របស់ខ្លួន ។

ក្នុងករណីដែលអគ្គសវនករ ឬអគ្គសវនកររងទទួលអនិច្ចកម្មឬលាលែងឬបាត់បង់សមត្ថភាព ពលកម្ម ឬមានកំហុសជាទម្ងន់នោះ ត្រូវជ្រើសតាំងអគ្គសវនករ ឬអគ្គសវនកររងថ្មីជំនួសតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់នេះ ។

អគ្គសវនករមានឋានៈនិងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និងអគ្គសវនកររងមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។

មាត្រា ១៩ ._

បេក្ខជនដែលត្រូវជ្រើសរើសមកតែងតាំងជាអគ្គសវនករ អគ្គសវនកររងត្រូវជាឥស្សរជន :

-មានសញ្ជាតិខ្មែរពីកំណើត

-មានសញ្ញាប័ត្រពីថ្នាក់ឧត្តមសិក្សាឡើងទៅ ឬសញ្ញាប័ត្រសមមូលផ្នែកគណនេយ្យ ឬសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ ឬច្បាប់ ឬពាណិជ្ជកម្មដែលមានបញ្ជាក់ទទួលស្គាល់ច្បាស់លាស់

-មានបទពិសោធន៍ខាងវិជ្ជាជីវៈ ឬការងារយ៉ាងតិច ១០ ( ដប់ ) ឆ្នាំឡើងទៅ

-មិនមានតួនាទីក្នុងអង្គការដឹកនាំនៃគណបក្សនយោបាយណាមួយ ។

មាត្រា ២០ ._

អគ្គសវនករមានតួនាទីជាអ្នកដឹកនាំនៃអាជ្ញាធរសវនកម្មជាតិ ដែលត្រូវទទួលខុសត្រូវលើការអនុវត្តន៍គោលនយោបាយ គោលដៅ គោលបំណងរបស់អាជ្ញាធរសវនកម្មជាតិ និងមានសិទ្ធិដើម្បីធ្វើសកម្មភាពលើរាល់កិច្ចការទាំងអស់ដែលមានចែងនៅក្នុងច្បាប់នេះ ។

មាត្រា ២១ ._

អគ្គសវនករជាអ្នកតែងតាំង ផ្លាស់ប្តូរ ធ្វើកម្មវិធាកនិងកំណត់បៀវត្សរ៍ អត្ថប្រយោជន៍ ប្រាក់កំរៃ ប្រាក់រង្វាន់ ដល់មន្ត្រីរាជការនិងបុគ្គលិករបស់អាជ្ញាធរសវនកម្មជាតិ ។

## ជំពូកទី ៥
## របាយការណ៍នៃសវនកម្ម

មាត្រា ២២ ._

រាជរដ្ឋាភិបាលត្រូវបញ្ជូនឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ ទៅរដ្ឋសភា ព្រឹទ្ធសភាដើម្បីពិនិត្យនិងអនុម័ត ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏ត្រូវបញ្ជូនឯកសារនេះទៅអាជ្ញាធរសវនកម្មជាតិដើម្បីធ្វើសវនកម្មដែរ ។ អាជ្ញាធរសវនកម្មជាតិត្រូវធ្វើរបាយការណ៍សវនកម្មបញ្ជាក់លើឯកសារនេះទៅរដ្ឋសភា ព្រឹទ្ធសភា ។

មាត្រា ២៣ ._

បើក្នុងរយៈពេល ៤ ( បួន ) ខែបន្ទាប់ពីដំណាច់ឆ្នាំនៃការិយបរិច្ឆេទ រាជរដ្ឋាភិបាលមិនបានផ្តល់ឯកសារស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំមកអាជ្ញាធរ សវនកម្មជាតិទេ អគ្គសវនករត្រូវធ្វើរបាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភាស្តីពីការខកខាននេះ ។

មាត្រា ២៤ ._

អគ្គសវនករត្រូវរាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ក្នុងករណីដែលអង្គភាពណាមួយមានភាពមិនប្រក្រតីនៅក្នុងកិច្ចប្រតិបត្តិការគណនេយ្យ ការគ្រប់គ្រងរូបិយវត្ថុ និងទ្រព្យសកម្ម ។

មាត្រា ២៥ ._

អគ្គសវនករត្រូវធ្វើរបាយការណ៍និងធ្វើកំណត់សំគាល់ជាទូទៅលើបណ្តាបញ្ហាដែលទាក់ទងដល់កិច្ចបញ្ជីកាគណនេយ្យ រូបិយវត្ថុ ប្រព្រឹត្តកម្ម និងបំណុលអកម្មផ្សេងៗទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ។

មាត្រា ២៦ ._

ទោះបីជាមានបទប្បញ្ញត្តិណាផ្សេងៗទៀតក៏ដោយដែលស្តីពីសវនកម្ម អគ្គសវនករធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យរបស់អាជ្ញាធរ ឬស្ថាប័ននោះ ត្រូវផ្តល់លិខិតបញ្ជាក់និងរបាយការណ៍ផ្សេងទៀត ដែលយល់ថាជាការចាំបាច់ចំពោះកិច្ចបញ្ជីកាគណនេយ្យនោះ ទៅឲ្យអ្នកដឹកនាំអាជ្ញាធរ ឬស្ថាប័ននោះ និងទៅរដ្ឋសភា ព្រឹទ្ធសភានិងក្រសួងពាក់ព័ន្ធ ។

មាត្រា ២៧ ._

អគ្គសវនករត្រូវរាយការណ៍ជូនរដ្ឋសភា ព្រឹទ្ធសភាជាប្រចាំនូវបញ្ហាទាំងឡាយណាដែលកើតចេញពីការបំពេញភារកិច្ច ឬប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់នេះ ។

មាត្រា ២៨ ._

ក្រោយពីមានការរៀបចំរបាយការណ៍ស្តីពីសវនកម្មនៃកិច្ចប្រតិបត្តិការរបស់អង្គភាពណាមួយ អគ្គសវនករត្រូវជូនច្បាប់ចំលងរបាយការណ៍នោះទៅប្រធានស្ថាប័នគ្រប់គ្រង ។ ប្រសិនបើប្រធានស្ថាប័នគ្រប់គ្រងនោះបានជូនយោបល់ជាលាយលក្ខណ៍អក្សរទៅអគ្គសវនករ ក្នុងអំឡុងពេល ២៨ ( ម្ភៃប្រាំបី ) ថ្ងៃ អគ្គសវនករត្រូវពិចារណាលើយោបល់ទាំងនោះ មុនពេលរៀបចំរបាយការណ៍ចុងក្រោយ ។ ផ្ទុយទៅវិញ បើប្រធានស្ថាប័ននោះមិនឆ្លើយតបតាមការកំណត់ខាងលើ របាយការណ៍នោះត្រូវចាត់ទុកជាបានការ ។

មាត្រា ២៩ ._

របាយការណ៍ដែលធ្វើដោយអគ្គសវនករ ត្រូវបានចាត់ទុកជាឯកសារសាធារណៈ ។

## ជំពូកទី ៦
## សិទ្ធិអំណាចលើការប្រមូលព័ត៌មាន

មាត្រា ៣០ ._

អគ្គសវនករអាចតម្រូវតាមរយៈលិខិតទៅប្រធាន ឬតំណាងស្ថាប័នពាក់ព័ន្ធអោយ :

ក-ផ្តល់ដល់អគ្គសវនករ ឬមន្ត្រីមានការអនុញ្ញាតនូវព័ត៌មានអ្វីដែលត្រូវការ ។ មន្ត្រីមានការអនុញ្ញាត គឺមន្ត្រីដែលអគ្គសវនករបានអនុញ្ញាតជាលាយលក្ខណ៍អក្សរអោយអនុវត្តមុខនាទីនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

ខ-ចូលរួមនិងប្រគល់ភស្តុតាងចំពោះមុខអគ្គសវករ ឬ មន្ត្រីមានការអនុញ្ញាត ។

គ-ប្រគល់រាល់ឯកសារនានា ក្រោមការគ្រប់គ្រងរបស់ប្រធាន ឬតំណាងស្ថាប័នពាក់ព័ន្ធនេះទៅអគ្គសវនករ ឬមន្ត្រីមានការអនុញ្ញាត ។

មាត្រា ៣១ ._

អគ្គសវនករអាចតម្រូវអោយ :

ក-ផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬជាលាយលក្ខអក្សរហើយបញ្ជាក់ថា ត្រឹមត្រូវនៅចំពោះមុខច្បាប់ ។

ខ-អគ្គសវនករមានសិទ្ធិបញ្ជាក់រកការពិតនូវព័ត៌មាន និងរកភស្តុតាងជាក់លាក់ដែលបានផ្តល់ទាំងនោះ ។

មាត្រា ៣២ ._

អគ្គសវនករ ឬមន្ត្រីមានការអនុញ្ញាត :

ក-អាចចូលនិងស្ថិតនៅអង្គភាពដែលត្រូវធ្វើសវនកម្មគ្រប់ពេលម៉ោងធ្វើការ ។

ខ-មានសិទ្ធិពេញលេញនិងផែកធេរដោយសេរីរាល់ឯកសារ របាយការណ៍ ឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ក្រសួងស្ថាប័នទាំងនោះ ។

គ-អាចត្រួតពិនិត្យថតចំលង ឬដកស្រង់ឯកសារពីរបាយការណ៍ណាមួយក៏បាន ។

មាត្រា ៣៣ ._

មន្ត្រីដែលមានការអនុញ្ញាត មុនពេលចូល និងស្ថិតនៅអង្គភាពដែលត្រូវធ្វើសវនកម្ម ត្រូវបង្ហាញលិខិតអនុញ្ញាតដែលចុះហត្ថលេខាដោយអគ្គសវនករ ។ ម្ចាស់ស្ថាប័នឬអង្គភាពត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីមានការអនុញ្ញាត ក្នុងការធ្វើសវនកម្មនៅពេលបានឃើញលិខិតអនុញ្ញាតនេះ ។

មាត្រា ៣៤ ._

ត្រូវហាមឃាត់ចំពោះអ្នកផ្តល់ព័ត៌មាននូវការក្លែងបន្លំរបាយការណ៍ ទោះជារបាយការណ៍ផ្ទាល់មាត់ ឬជាលាយលក្ខអក្សរ ។

## ជំពូកទី ៧
## ការសម្ងាត់នៃព័ត៌មាន

មាត្រា ៣៥ ._

ប្រសិនបើមន្ត្រីមានការអនុញ្ញាតណាមួយបានទទួលព័ត៌មានដោយផ្ទាល់ ឬដោយប្រយោលក្នុងដំណើរនៃការអនុវត្តន៍មុខនាទីមួយនៅក្នុងច្បាប់នេះ មន្ត្រីនោះមិនត្រូវលាតត្រដាងបកស្រាយ ឬផ្តល់ព័ត៌មានទៅមជ្ឈដ្ឋានខាងក្រៅឡើយ លើកលែងតែការអនុវត្តន៍មុខនាទីភារកិច្ចផ្ទៃក្នុងរបស់អាជ្ញាធរសវនកម្មជាតិ ។

មាត្រា ៣៦ ._

ការហាមឃាត់នៅក្នុងមាត្រា ៣៥ នៃច្បាប់នេះ ពុំមានប៉ះពាល់ទៅលើការលាតត្រដាង ការបកស្រាយ ការផ្តល់ព័ត៌មាននៅក្នុងរបាយការណ៍នូវសេចក្តីសន្និដ្ឋាន ការកត់សំគាល់ ឬការសង្កេតរបស់អគ្គសវនករឡើយ ។

មាត្រា ៣៧ ._

អគ្គសវនករមិនត្រូវបញ្ចូលព័ត៌មានពីស្តារនៅក្នុងរបាយការណ៍ដែលត្រូវផ្សព្វផ្សាយ ជាសាធារណៈទេ ប្រសិនបើ :

ក-អគ្គសវនករយល់ថា ការលាតត្រដាងព័ត៌មានគឺជាការផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ លើហេតុផលណាមួយដែលមានបញ្ជាក់នៅក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

ខ-រាជរដ្ឋាភិបាលបានចេញលិខិតបញ្ជាក់មួយទៅអគ្គសវនករថា ការលាតត្រដាងព័ត៌មាននេះ គឺជាការផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ តាមហេតុផលណាមួយដែលមានបញ្ជាក់នៅក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

មាត្រា ៣៨ ._

ក្នុងគោលបំណងនៃមាត្រា ៣៧ នៃច្បាប់នេះ ហេតុផលខាងក្រោមនេះត្រូវបានចាត់ទុកថាជាព័ត៌មានដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ៖

ក-ប៉ះពាល់ដល់សន្តិសុខ ការការពារជាតិ និងបូរណភាពទឹកដី ឬទំនាក់ទំនងអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

ខ-ប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់បណ្តាអង្គភាព ឬ បុគ្គល ។

មាត្រា ៣៩ ._

យោងតាមមាត្រា ៣៧ នៃច្បាប់នេះ អគ្គសវនករសម្រេច :

ក-មិនរៀបចំរបាយការណ៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ ។

ខ-លុបចោលព័ត៌មានពីស្តារក្នុងរបាយការណ៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ ។

ប៉ុន្តែចំពោះរបាយការណ៍បង្ហាញជូនរដ្ឋសភា ព្រឹទ្ធសភា ឬក្រសួងពាក់ព័ន្ធ អគ្គសវនករ ត្រូវរៀបចំបញ្ចូលព័ត៌មានពីស្តារដែលបានលោមបកដូចមានចែងនៅក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

## ជំពូកទី ៩

## សវនកម្មលើអាជ្ញាធរសវនកម្មជាតិ

មាត្រា ៤០ ._

ក្នុងករណីចាំបាច់ តាមសំណើរបស់គណៈកម្មការហិរញ្ញវត្ថុនិងធនាគារនៃរដ្ឋសភាគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងនាមនៃរដ្ឋសភាមានសិទ្ធិជ្រើសរើសសវនករពិសេស ដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាពនិងកិច្ចប្រតិបត្តិការរបស់អាជ្ញាធរសវនកម្មជាតិ ។

## ជំពូកទី ៩
## ការបង្កើតសវនកម្មផ្ទៃក្នុង

**មាត្រា ៤១ .-**

សវនកម្មផ្ទៃក្នុងត្រូវបង្កើតឡើងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។ សវនកម្មផ្ទៃក្នុងត្រូវធ្វើរបាយការណ៍ទៅប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះ ទៅអាជ្ញាធរសវនកម្មជាតិ ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤២ .-**

សវនកម្មផ្ទៃក្នុងមានភារកិច្ចធ្វើការពិនិត្យវាយតំលៃដោយឯករាជ្យ លើប្រសិទ្ធភាព ក្នុងការអនុវត្តន៍ នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់បណ្តាស្ថាប័ន ក្រសួងនិងសហគ្រាសសាធារណៈ ។

**មាត្រា ៤៣ .-**

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការរបស់រាជរដ្ឋាភិបាល ដែលធ្វើឡើងដោយថ្នាក់ដឹកនាំស្ថាប័ន ក្រសួងនិងសហគ្រាសសាធារណៈ ដើម្បីផ្តល់នូវការធានាភាពសមស្របលើសមិទ្ធកម្មវត្ថុ នៃកម្មវត្ថុ តាមបណ្តាផ្នែកខាងក្រោម :

ក-ប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ ។

ខ-ភាពទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ ។

គ-ភាពសមស្របតាមបណ្តាច្បាប់ បទបញ្ជា គោលនយោបាយ នីតិវិធី និងការចាត់ចែងដែលត្រូវអនុវត្ត ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**មាត្រា ៤៤ .-**

ដោយពុំទាន់គិតដល់ការផ្តន្ទាទោសផ្សេងទៀត ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣២ ឬមាត្រា ៣៣ នៃច្បាប់នេះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០ ( មួយលាន ) រៀលទៅ ៥.០០០.០០០ ( ប្រាំលាន)រៀល ឬដាក់ពន្ធនាគារពី ១ (មួយ) ខែដល់ ៣ ( បី ) ខែ ឬពិន័យជាប្រាក់ផង និងដាក់ពន្ធនាគារថែមទៀតផង ។

**មាត្រា ៤៥ .-**

ដោយពុំទាន់គិតដល់ការផ្តន្ទាទោសផ្សេងទៀត ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៤ នៃច្បាប់នេះ និងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ៥.០០០.០០០ ( ប្រាំលាន ) រៀលឡើងទៅ ឬដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំដល់ ៥ ( ប្រាំ) ឆ្នាំ ឬពិន័យជាប្រាក់ផងនិងដាក់ពន្ធនាគារថែមទៀតផង ។

ជំពូកទី ១១

អវសានប្បញ្ញត្តិ

មាត្រា ៤៦ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤៧ ._

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

★★★

# ២- ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៦

### ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

យើង

ព្រះបាទសម្តេចព្រះនរោត្តមសីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ក ដូចបានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ ._**

ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាក្រសួង ស្ថាប័ននានា។ ឯការវិវត្តន៍របស់មន្ត្រីម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួង ស្ថាប័នសាមី។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌសំរាប់ធ្វើការងារគ្រប់គ្រងរដ្ឋបាលផ្សេងពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ ។

**មាត្រា ៣ ._**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មានឧបនិស្ស័យសំរាប់កាន់មុខតំណែងដឹកនាំ និងទទួលខុសត្រូវធ្វើអធិការកិច្ច ធ្វើការសិក្សា និងផ្តល់យោបល់ ក្នុងអង្គភាពរដ្ឋបាល គតិយុត្ត សេដ្ឋកិច្ច បច្ចេកទេស និងសង្គមកិច្ច នៃ រដ្ឋបាលកណ្តាល និងខេត្តក្រុង ស្របតាមមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះ ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។ មន្ត្រីក្នុងក្របខ័ណ្ឌក៏មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងនៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ ។

## ជំពូកទី ២
## ឋានន្តរស័ក្តិ និង មុខតំណែង

មាត្រា ៤ ._

ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មាន ៣ ឋានន្តរស័ក្តិ ៖

-ឧត្តមមន្ត្រី មាន ៦ នាក់

-វរៈមន្ត្រី មាន ១០ នាក់

-អនុមន្ត្រី មាន ១៤ នាក់ ។

មាត្រា ៥ ._

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

-អគ្គនាយក

-អគ្គាធិការ

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ វរៈមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

-អគ្គនាយករង

-អគ្គាធិការរង

-ប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាល

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គភាពលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិអនុមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

-អនុប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាល

-ប្រធានមន្ទីរនៅខេត្ត ក្រុង

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

## ជំពូកទី ៣
## ការជ្រើសរើស

មាត្រា ៦ ._

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការ និង ឬក្នុងចំណោមនិស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់

បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជានិស្សិត ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៧ ._

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ៣០ ឆ្នាំគិតមកដល់ថ្ងៃប្រឡង ហើយដែលមានសញ្ញាប័ត្រទាបបំផុតស្មើសញ្ញាបរិញ្ញាប័ត្រ ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការត្រូវបើកចំហចំពោះមន្ត្រីទាំងឡាយ ដែលស្ថិតយ៉ាងតិចបំផុតក្នុងថ្នាក់លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ ខ និងមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌដែលមានសញ្ញាប័ត្រស្មើនឹងបរិញ្ញាប័ត្រអាចប្រឡងប្រជែងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតលក្ខខ័ណ្ឌឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។

## ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និងការតាំងស៊ប់

មាត្រា ៨ ._

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងឬក្នុងចំណោម និស្សិតមានឋានៈជាសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាល ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅភូមិន្ទរដ្ឋបាល ។

មាត្រា ៩ ._

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលត្រូវបានចាត់អោយទៅបំពេញការងារតាមក្រសួង ស្ថាប័ននានាហើយត្រូវបានតែងតាំងជាមន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សា ដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេលដូចខាងក្រោមនេះ ៖

១-១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត ។

២-៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌក្រមការ ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុខនេះស្ថិតក្នុងក្របខ័ណ្ឌក្រមការពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងមន្ត្រីដែលចែងក្នុងចំណុចទី១ និងទី២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី ។ ក្នុងករណីពិសេសអាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម១២ ខែចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង៦ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចោល

ប្រសិនបើចេញមកពីនិស្សិត ឬមួយបញ្ចូលទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលទាំងអតីតភាពការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រោយពីមានសំណើរបស់ក្រសួង ស្ថាប័នសាមី ដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើង ក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិអនុមន្ត្រី ។

មន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោម មន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០ ._**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរួចហើយ មន្ត្រីគ្រប់គ្រងរដ្ឋបាលទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា ៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចបានកំណត់ក្នុងមាត្រា ១៤ និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

**មាត្រា ១១ ._**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលអាចផ្លាស់ប្តូរពីក្រសួងស្ថាប័នមួយទៅក្រសួងស្ថាប័នមួយទៀតតាមការស្នើសុំរបស់សាមីខ្លួន ឬតាមតម្រូវការការងារ ដោយមានការឯកភាពរបស់ក្រសួងស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ហើយត្រូវសំរេចដោយប្រកាស ឬអនុក្រឹត្យ ឬព្រះរាជក្រឹត្យ ។

ការផ្លាស់ប្តូរនេះ ជាគោលការណ៍អាស្រ័យដោយតំណែងដែលមាននៅទំនេរក្នុងក្រសួង ស្ថាប័នមួយទៀត ឬដោយសំណូមពរការងារចាំបាច់ ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១២ ._**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ៖

-មានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត
-មានស្មារតីទទួលខុសត្រូវ
-យកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
-មានប្រសិទ្ធភាពក្នុងការដឹកនាំ
-មានសីលធម៌ល្អ

ការឡើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រា ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

ចំពោះការតម្លើងថ្នាក់ ៖
-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីត្រូវសំរេចដោយព្រះរាជក្រឹត្យ
-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ វរៈមន្ត្រីត្រូវសំរេចដោយអនុក្រឹត្យ
-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រីត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១៣ .-**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលមានទំនេរ នៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬ ក្រៅប្រទេស ។

ការតម្លើងឋានន្តរស័ក្តិអនុមន្ត្រីទៅវរៈមន្ត្រីត្រូវសំរេចដោយអនុក្រឹត្យ ហើយការតម្លើងឋានន្តរស័ក្តិពីវរៈមន្ត្រី ទៅឧត្តមមន្ត្រី ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

**មាត្រា ១៤ .-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិអនុមន្ត្រី ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិឧត្តម គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិវរៈមន្ត្រី ។

ការតម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាង អាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់កាន់មុខតំណែងស្របតាមឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា ៥ នៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា ១៥ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងតំលៃឯកតានៃសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៦ ._

មន្ត្រីនៃក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលបំរើការងាររដ្ឋបាលរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ។

ចំពោះការដាក់អោយចូលនិវត្តន៍ ៖

-ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ត្រូវសំរេចដោយព្រះរាជក្រឹត្យ

-ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ត្រូវសំរេចដោយអនុក្រឹត្យ

-ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ១៧ ._

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

មាត្រា ១៨ ._

សញ្ញាស័ក្តិនិងឯកសណ្ឋានសំរាប់មន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

មាត្រា ១៩ ._

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាល និងខេត្តក្រុង ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ២០ ._

រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២១ .-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់បង្គាប់

ព្រះមហាក្សត្រ ឡាយព្រះហស្តលេខា ប្រមុខរដ្ឋស្តីទី

នាយករដ្ឋមន្ត្រី ហត្ថលេខា

ហត្ថលេខា ជា ស៊ីម

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា

ពេជ្រ ប៊ុនធិន

★★★

## ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .-** ត្រូវបានតែងតាំងឯកឧត្តម **ឌិ គុសល:** បច្ចុប្បន្នជាទីប្រឹក្សារបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដោយមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះឲ្យបានសំរេច ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែ មីនា ឆ្នាំ២០០០

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

**ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៨**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១-១២-១៣-១៨-២២-២៥-២៦-២៨-៣០-៣៤-៥១-៩០-៩១-៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងឯកឧត្តម **ហុង ឡុង** ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី២ នៃព្រឹទ្ធសភាជំនួស ឯកឧត្តម **សំ គីមហេង** ដែលបានស្នើសុំលាឈប់ពីមុខតំណែង ។

មាត្រា ២ ._ ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០០

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៩ អនក្រ.បក

**ស្តីពីវិសោធនកម្ម នៃអនុក្រឹត្យលេខ ០៧ អន.ក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រង់មាត្រា ១.២.៣ និង ៨ ពាក់ព័ន្ធទៅនឹងឯកសណ្ឋានកងទ័ពជើងគោក កងនាវាចរ កងអាកាសចរ ឯកសណ្ឋានត្រែទ័ព និង កងកិត្តិយស**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋានផ្លាកសញ្ញានិងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០០

**សំរេច**

មាត្រា ១ ._ ក្នុងមាត្រា១ថ្មីនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតម្រូវដូចខាងក្រោម ៖

ត្រូវបានរៀបចំឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទជាថ្មី ដូចខាងក្រោម ៖

**<u>រូបភាព ម៉ូតនិងប្រភេទឯកសណ្ឋាន</u> :**

ក-<u>ឯកសណ្ឋានថ្នាក់ឧត្តមសេនីយជើងគោក</u> :

១-<u>ឯកសណ្ឋានធំលេខ១</u> : ( អាវកុដ ស )

-អាវកុដស កត្រង់ ខោពណ៌ក្រមៅ មានឆ្នូតក្រហមពីរ ។

-អាវកុដស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ត្រូវផលិតកអាវដែលមានកំពស់ ៤ ស.ម ដោយប៉ាក់ភ្ជីទេសឱនពណ៌មាសជុំវិញពេញតួកអាវនិងប៉ាក់ផ្កាភ្ជីរាងកន្ទុយកណ្តុរព័ទ្ធជុំវិញមានទំហំ ០,៣ ស.ម ។ លើស្មាទាំងសង្ខាងមានប៉ូល ហោប៉ៅបួន(ហោប៉ៅពីរខាងលើដេរប៉ះ ចំកណ្តាល មានចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោមដេរបង្កប់ គំរបរាងចតុកោណកែង ) អាវដៃវែងកាត់ម៉ូតដៃបំពង់ លើថ្នេរដៃបត់ចុងដៃអាវមានប៉ាក់ភ្ជីទេសឱនពណ៌មាស ប៉ាក់រាងស្លឹកពោធិ ហើយចុងស្លឹកពោធិនោះត្រូវដាក់អោយចំពីលើខ្នងដៃ ។ ទំហំប៉ាក់ចាប់ពីចុងដៃអាវរហូតដល់ចុងស្លឹកពោធិមានកំពស់ ៩ ស.ម ផ្នែកខាងក្រោយចុងដៃអាវត្រូវប៉ាក់មកលើកំពស់ ៤,៥ ស.ម ។ នៅជុំវិញភ្ជីទេសឱនត្រូវប៉ាក់ផ្កាភ្ជីរាងកន្ទុយកណ្តុរព័ទ្ធជុំវិញមានទំហំ ០,៣ ស.ម ឡេវអាវមានរូបព្រះសង្ការពណ៌មាស ( ឡេវធំពីកអាវមកដល់ក្រោមចំនួន ៦ ឡេវហោប៉ៅចំនួន ៤ ឡេវប៉ូលស្មាទាំងសង្ខាងនិងដាក់បញ្ឆោតនៅចុង ដៃអាវនីមួយៗ៣ម្ខាង ) ។

-ខោជើងវែងចង្កេះត គ្មានភ្លី នៅខាងក្រោយមានហោប៉ៅមួយដេរបង្កប់គ្មានគំរប ហោប៉ៅពីរនៅចំហៀងដេរបង្កប់តាមថ្នេរខោទាំងសង្ខាង ពីចង្កេះដល់ចុងជើង ខោមានឆ្នូតពណ៌ក្រហមពីរ ឆ្នូតនីមួយៗមានទំហំ ២ ស.ម ឃ្លាត ពីគ្នាចម្ងាយ ០,៥ ស.ម ។

-មួកកាសស្តេត ពណ៌ក្រមៅ ក្រណាត់កាំម្ទី ជើងមួកពណ៌ក្រហម ហាមមួកធ្វើពីកៅស៊ូរឹងពណ៌ខ្មៅ នៅលើហាមមួកមានប៉ាក់ភ្ជីទេសឱនពណ៌មាសដល់ជើងមួក រំណ្ឌខាងមុខនិងឡេវ (រូបព្រះសង្ការ ) ពណ៌មាស ។

-ស្បែកជើងប្លែប ពណ៌ខ្មៅ ធ្វើអំពីស្បែក កខ្លី ។

-ស្រោមជើងពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

-ខ្សែរំយោល ពណ៌មាសវេញចូលគ្នារាងសំប៉ែត ខ្សែអមបីមានមូលបន្តោកពីរពណ៌មាស មានក្បាច់ផ្កាភ្ជី ។

-ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ក្បាលខ្សែក្រវាត់ធ្វើអំពីលោហធាតុលាតពណ៌មាស ( ប្រើគ្រប់ឯកសណ្ឋានទាំងអស់ ) ។

-ចំពោះនារី អាវមានគំរូដូចបុរស តែកាត់រាងតាមដងខ្លួននារី សំពត់ព្យើបក្រោមជង្គង់ពណ៌ក្រមៅ មានឆ្នូតក្រហមសង្ខាងដូចគ្នា ។

២-<u>ឯកសណ្ឋានធំលេខ ២</u> : ( អាវវ៉ារី )

-ឯកសណ្ឋានធំលេខ ២នេះ ពណ៌ត្រែអ៊ី អាវសឺមីក្នុងពណ៌ត្រែអ៊ីខ្ចី ក្រវាត់កពណ៌ខ្មៅ ។

-អាវកាត់រាងអាវវ៉ារី មានផែកខ្នងមួយ កបើកប៉ូលស្មាទាំងសង្ខាង មានហោប៉ៅបួន ( ហោប៉ៅពីរខាងលើដេរប៉ះ ចំកណ្តាលមានចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោមដេរបង្កប់មានគំរបរាងចតុកោណ

កែង ) ដៃអាវវែងកាត់រាងដៃបំពង់ ។ ឡេវអាវមានរូបព្រះសង្ការ ឡេវធំប្អូន ឡេវហោជៅប្អូន ឡេវ តូចប៉ុលេស្នាពីរ និងឡេវបញ្ឆោតនៅចុងដៃអាវម្ខាងបី ។

-ខោជើងវែង ពណ៌ត្រែអ៊ី ថ្នេរបង្កប់ ចង្កេះត គ្មានភ្លី មានហោជៅប្អូន ( ហោជៅពីរខាងក្រោយដេរបង្កប់ មានគំរបរាងស្លឹកពោធិ នៅចំហៀងពីរ ដេរបង្កប់តាមថ្នេរខោ ) ។

-មួកកាសស្កេត ពណ៌ត្រែអ៊ី ជើងមួកពណ៌ខ្មៅ បាមមួកធ្វើអំពីជ័រវីងពណ៌ខ្មៅ រ័ណ្ណនឹងឡេវមួក ( រូបព្រះសង្ការ ) ពណ៌មាស លើបាមមួកមានបាំកក្បាច់ភ្ញីទេសឪនដប់ជើងមួកទាំងសងខាង ។

-អាវសឺមីក្នុង ពណ៌ត្រែអ៊ីខ្ចី កាត់ស្រុងវែងដាក់ក្នុងខោ មានហោជៅមួយនៅខាងឆ្វេង គ្មានគំរប ដៃអាវកាត់ផែកដាក់ឡេវបិទ ។

-ក្រវាត់ កពណ៌ខ្មៅ ស្រោមដៃ ពណ៌ស ។

-ស្បែកជើងឃ្លុប ពណ៌ខ្មៅ ធ្វើពីស្បែក កខ្ចី ។

-ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ក្បាលខ្សែក្រវាត់លោហធាតុលោត ពណ៌មាស ។

-ចំពោះនារី អាវដូចខាងលើ តែជីបចង្កេះ និងកអាវ តាមរាងជងខ្លួន សំពត់ហ្សីបក្រោមជង្គង់ ។

៣-ឯកសណ្ឋានលេខ ៣ : ( សាលាកេរីយែន )

-ឯកសណ្ឋាននេះទាំងអាវនិងខោ ពណ៌ត្រែអ៊ី ហោជៅប្អូន ។

-អាវដៃខ្លី កបើក ខាងក្រោយមានផែក និងមានប៉ានចង្កេះ ផ្នែកខាងមុខហោជៅប្អូន ( ពីរខាងលើ និងពីរខាងក្រោម ហើយហោជៅអាវនិងគំរបត្រូវដេររាងមូល ប៉ូលេស្នាទាំងសងខាង ឡេវរូបព្រះសង្ការ ពណ៌មាស ) ។

-ខោជើងវែង ពណ៌ត្រែអ៊ី ( កាត់ម៉ូតដូចឯកសណ្ឋានលេខ ២ ) ។

-មួក ស្បែកជើង និងស្រោមជើង ( ដូចឯកសណ្ឋានលេខ ២ ) ។

-ចំពោះនារី អាវដូចបុរស តែជីបចង្កេះតាមរាងនារី ហើយសំពត់ហ្សីបពណ៌ត្រែអ៊ី ក្រោមជង្គង់ ។

៤-ឯកសណ្ឋានការងារ ( លេខ ៤ ) : គំរូឯកសណ្ឋាននេះមានតែមួយសំរាប់គឺ ÷

-ឯកសណ្ឋានការងារ អាវពណ៌ត្រែអ៊ី ដៃខ្លី ហើយខោពណ៌ត្រែអ៊ី ។

-អាវដៃខ្លី ពណ៌ត្រែអ៊ី កឌុប ប៉ូលេស្នាទាំងសងខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោជៅពីរដេរប៉ះ ចំកណ្តាលដេរបត់ផ្នត់មួយ មានគំរបរាងស្លឹកពោធិ ឡេវធម្មតាពណ៌ត្រែអ៊ី ។

-ខោជើងវែង ( ដូចឯកសណ្ឋានលេខ ៣ ) ពណ៌ត្រែអ៊ី ។

-មួកបេរេ ពណ៌ត្រែអ៊ី នៅស្រទាប់មួកមានចំពណ៌មាសតាមបណ្តោយទំហំ ៨ម.ម ។

-ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ( ដូចខ្សែក្រវាត់ឯកសណ្ឋានលេខ ១ ) ។

-ចំពោះនារី អាវដូចបុរស ខោជើងវែង កាត់ដូចបុរស តែខុសចំពោះនារី ផែក ឡេវចំហៀងឬសំពត់ ហ្សីបពណ៌ត្រែអ៊ី ក្រោមជង្គង់ ។

៥-ឯកសណ្ឋានប្រយុទ្ធ ៖

-គំរូឯកសណ្ឋានប្រយុទ្ធ មានតែមួយសំរាប់ អាវដៃវែង ហោប៉ៅបួន ខោជើងវែង ហោប៉ៅប្រាំមួយ ជើងខោចងខ្សែ ឬដាក់ខ្សែយឺតរិតជើង ពណ៌ត្រេអ៊ី ជើងគោក (ទ័ពពិសេស ស៊ើបការ ទ័ពការពារព្រំដែន និងឆ័ត្រយោង ពណ៌កាំម៉ូផ្លា ) ដោយឡែកថ្នាក់ឧត្តមសេនិយ ជាអទិភាពពាក់ប៉ានទាំងអស់ ។

-អាវដៃវែង កបើក ថ្នេរឌុប ហោប៉ៅបួន ដេរឃោគមកក្រៅទាំងអស់ មានគំរបរាងចតុកោណកែង ឡេវទាំងអស់ដាក់បង្កប់ ពណ៌ត្រេអ៊ី ដៃអាវវែង កាត់ដៃបំពង់ មានក្រវាត់និងឡេវ លើស្មាមានប៉ូលពីរសង្ខាង ។

-ខោជើងវែង ថ្នេរឌុប ហោប៉ៅក្រោយពីរ ដេរបង្កប់ មានគំរបរាងចតុកោណកែង នៅចំហៀងតាមថ្នេរខោដេរបង្កប់មាត់ហោប៉ៅបញ្ឆិត ប៉ានជង្គង់ នៅសង្ខាងភ្លៅមានហោប៉ៅធំពីរ នៅជើងម្ខាងមួយ ផ្នែកខាងក្រៅហោប៉ៅដេរឃោគមកក្រៅ នៅកណ្តាលហោប៉ៅមានបត់ផ្នត់ពីរជាន់ គំរបរាងចតុកោណកែង ដាក់ឡេវពីរ ជើងខោចងខ្សែ ឬខ្សែយឺត ។

-មួកដែកនិងមួកបេរ៉េកពីពណ៌ត្រេអ៊ី ( ទ័ពពិសេស ទ័ពការពារព្រំដែននិងឆ័ត្រយោង ពណ៌កាំម៉ូផ្លា ) ហើយមួកបេរ៉េក នៅលើហាមមួករបស់ឧត្តមសេនិយមានប៉ាក់ភ្ញីទេសឌិន ដូចមួកពាសស្តេតដែរ ។

-ស្បែកជើងស្បែក កវែង ពណ៌ខ្មៅ ។

-ស្រោមជើងពណ៌ត្រេអ៊ី ។

-កន្សែងរុំក ( ហ្វូឡា ) ពណ៌ត្រេអ៊ី ក្រណាត់នីឡុង ។

-ប៉េរ៉េពណ៌ត្រេអ៊ី ជើងគោក ទ័ពពិសេស ឆ័ត្រយោងពណ៌ក្របរអេ ។

ខ-ឯកសណ្ឋានថ្នាក់វរសេនិយ ៖

១-ឯកសណ្ឋានលេខ១ ៖ ដូចថ្នាក់ឧត្តមសេនិយដែរ តែមានចំណុចមួយចំនួនខុសគ្នាដូចខាងក្រោម ៖

-ប៉ាក់ភ្ញីទេសឌិននៅលើកអាវខាងចុងបិទឡេវទាំងសង្ខាង ខាងដើមត្រូវប៉ាក់ទំហំ ៣ ស.ម ហើយបញ្ឆិតទៅលើប្រវែង ៧ ស.ម ដោយគិតពីខាងដើមមក ។

-នៅចុងដៃអាវមានប៉ាក់ភ្ញីទេសឌិនដូចថ្នាក់ឧត្តមសេនិយដែរ តែទំហំតូចជាងថ្នាក់ឧត្តមសេនិយចំនួនពាក់កណ្តាល ។

-មួក នៅលើហាមមួក ក្បាច់ភ្ញីទេសឌិន នៅចុងហាមមួកទុកចន្លោះពីជើងមួកសង្ខាង ប្រវែង ៥ ស.ម ។

-ខ្សែរំយោលវេញចូលគ្នាបីខ្សែដៃ តែទំហំតូចជាងថ្នាក់ឧត្តមសេនិយ ។

-ខោជើងវែងពណ៌ក្រមៅ ថ្នាក់វរសេនិយមានឆ្នូតពីរ ឆ្នូតនីមួយៗទទឹង១ ស.ម ។

២-ឯកសណ្ឋានលេខ ២+៣ ៖ រូបភាព ម៉ូត ពណ៌ ដូចថ្នាក់ឧត្តមសេនិយ តែខុសគ្នានៅហាមមួក ក្បាច់ភ្ញីទេសឌិនទុកចន្លោះពីដើមមួកសង្ខាង ៤ ស.ម ។

៣-ឯកសណ្ឋានលេខ ៤ ( អាវការងារ ) ៖ ដូចគ្នាឧត្តមសេនិយ តែខុសគ្នាមួកបោណេ នៅស្រែទាប់មួកថ្នេរមានចំពណ៌ក្រហមទំហំ៥ស.ម ។

៤-ឯកសណ្ឋានប្រយុទ្ធ : ដូចឧត្តមសេនីយ តែខុសគ្នា មួកបេរ៉េកកី ក្បាច់ភ្ញីទេសឱនៅលើមួក មុក ចន្លោះ៤ស.ម ពីជើងមួក ។

គ-ឯកសណ្ឋានថ្នាក់អនុសេនីយ :

១-ឯកសណ្ឋានលេខ១ : ដូចថ្នាក់ឧត្តមសេនីយដែរ តែមានចំណុចខុសគ្នាសំរាប់សំគាល់ថ្នាក់ដូចខាងក្រោម ៖

-ប៉ាក់ភ្ញីទេសឱនៅលើកអាវខាងចុងបិទឡេវទាំងសង្ខាង ខាងដើមត្រូវប៉ាក់កំពស់២ស.ម បញ្ឆិតឡើងស្តួចឡើងប្រវែង ៧ស.ម នៅត្រួចុងដែអាវមានចំណាំមាសទំហំ ១ស.ម ។

-មួកកាសស្តេត នៅលើមួកគ្មានក្បាច់ភ្ញីទេសឱនទេ តែមានចំជាធ្នូតពណ៌មាសនៅចុងលើ ប្រវែងទទឹងធ្នូតចំនួន ៦ម.ម ។

-ខោជើងវែងពណ៌ក្រមៅ ធ្នូតមានតែមួយ ប្រវែងទទឹងធ្នូត ២ស.ម ។

២-ឯកសណ្ឋានលេខ ២+៣ : ដូចថ្នាក់ឧត្តមសេនីយដែរ តែខុសគ្នាមួកកាសស្តេត លើមួកគ្មានក្បាច់ភ្ញីទេសឱនទេ មានចំធ្នូតពណ៌មាសនៅលើមួកដូចមួកកាសស្តេតឯកសណ្ឋានលេខ ១ដែរ ។

៣-ឯកសណ្ឋានការងារ : ដូចគ្នាឧត្តមសេនីយ តែមួកបោរណេចំពណ៌ទឹកប្រាក់ ។

៤-ឯកសណ្ឋានប្រយុទ្ធ : ដូចថ្នាក់ឧត្តមសេនីយដែរ តែមួកបេរ៉េកកីនៅលើមួកមានចំធ្នូតដូចមួកកាសស្តេតដែរ ។

ឃ-ថ្នាក់នាយទាហានរងនិងពលទាហាន :

-ក្នុងករណីណាៈដែលក្រសួងការពារជាតិនិងអគ្គមេបញ្ជាការពិនិត្យឃើញថា : ត្រូវបំពេញបេសកកម្មនៅក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ នាយទាហានរងនិងពលទាហានអាចមានឯកសណ្ឋានលេខ២ ឬលេខ៣ដែរ។ ចំពោះឯកសណ្ឋានទាំងនោះដូចថ្នាក់អនុសេនីយដែរ តែមួកកាសស្តេតគ្មានក្បាច់ភ្ញីទេសឱន ឬធ្នូតអ្វីទាំងអស់ ។

-ចំពោះនាយទាហានរងនិងពលទាហាន មានតែពាក់បំពាក់តែឯកសណ្ឋានការងារនិងឯកសណ្ឋានប្រយុទ្ធតែប៉ុណ្ណោះ ។ ចំពោះឯកសណ្ឋានការងារនិងប្រយុទ្ធដូចគ្នាថ្នាក់អនុសេនីយដែរ តែមួកបោរណេនិងបេរ៉េកកីគ្មានធ្នូតអ្វីទាំងអស់ ។ ចំពោះឯកសណ្ឋានការងារនិងប្រយុទ្ធដូចគ្នាថ្នាក់អនុសេនីយដែរ តែមួកបោរណេនិងបេរ៉េកកីគ្មានធ្នូតអ្វីទាំងអស់ ។

**មាត្រា ២ .-** ក្នុងមាត្រា២ថ្មីនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតម្រូវដូចខាងក្រោម :

ត្រូវបានរៀបចំឯកសណ្ឋានកងនាវាចរភូមិន្ទ និងអាកាសចរភូមិន្ទ ដូចខាងក្រោម ៖

ក-ឯកសណ្ឋានកងនាវាចរភូមិន្ទ កម្ពុជា :

-ឯកសណ្ឋានកងនាវាចរភូមិន្ទកម្ពុជា គ្រប់ឯកសណ្ឋាននិងគ្រប់ថ្នាក់ នាយទាហាន នាយទាហានរងនិងពលទាហានដូចទ័ពជើងគោក ខុសគ្នាតែពណ៌ប៉ុណ្ណោះ ។ ពណ៌ឯកសណ្ឋានកំណត់ដូចខាងក្រោម៖

-ឯកសណ្ឋានលេខ ១ លេខ ២ លេខ ៣ និងលេខ ៤ ( អាវកុដស អាវរ៉ាំ សាយការិយ៉ែន និង ការងារ ព្រួយោធ ស្បែកជើង និងស្រោមជើង ពណ៌សទាំងអស់ ។ ចំពោះអាវសីមីក្នុងរបស់ ឯកសណ្ឋានលេខ ២ ពេលតែមួយពណ៌សប៉ុណ្ណោះ ។ ដោយឡែកឯកសណ្ឋានការងារមាន ០២ សំរាប់ (ប៉ាតរ៉ាប់ពណ៌ស) ខ្សែក្រវាត់ តួចពណ៌ស ក្បាលខ្សែក្រវាត់លោតពណ៌មាស ។ ចំពោះនាយទាហានរង និងពលទាហាន អាវការងារពណ៌សកអាវទំលាក់មកក្រោមរាងជាកន្សែងវែងប្រវែង២៥ ស.ម ជុំវិញកអាវ នេះមានឆ្នូត៣ ពណ៌ខៀវ ឆ្នូតនិមួយៗមានទំហំ៨ ស.ម ។ ហើយពាក់មួកម៉ាតឺឡូពណ៌សជើងមួក ពណ៌ខៀវ លើជើងមួក សរសេរអក្សរពណ៌សថា (កងនាវាចរភូមិន្ទកម្ពុជា) កំពស់អក្សរ១៥ម.ម ។ ជើងមួកខាងក្រោយធែក មានខ្សែពីរសំរាប់ចងកន្ទុយខ្សែមានរាងកន្ទុយត្រី ។

-ចំពោះនាយទាហានត្រូវបានបន្ថែមឯកសណ្ឋានខ្មៅមួយសំរាប់ទៀតដែលមាន រូបភាព ម៉ូត អាវ កាត់បែបនាំអាវរ៉ាំ កបើក គ្មានធែកខ្នង គ្មានប៉ុលស្មា មានហោប៉ៅចំនួន៣ ( ហោប៉ៅលើក្រោមដេរបង្កប់ ) ឡេវមានរូបព្រះគង្ហារ ពណ៌មាស ពីរជួរខាងមុខ៣ម្ខាង ។ នៅចុងដៃអាវមានដេរសញ្ញាសក្តិចំងាយ៦ស.ម ឃ្លាតពីចុងដៃអាវឡើងមកលើតាមឋានន្តរសក្តិ ។

-សក្តិដៃអាវថ្នាក់ឧត្តមនាវីរលេចក្បាច់ផ្កាភ្ញី ៦ស.ម ពីចុងដៃអាវ ( ផ្កាភ្ញីមានទំហំ ១ស.ម ) ។ ផ្កាបថ្នាក់ឧត្តមនាវីពាក់លើផ្កាភ្ញីកំពស់ ១,២ ស.ម យ៉ាងទាបតាមចំនួនផ្កាយចំហៀងខាងក្រៅនៃដៃអាវ ។

-អាវសីមីពណ៌ស ក្រវាត់កពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

-មួកកាសស្កេតពណ៌ស តាមឋានន្តរសក្តិ ។

-ខោជើងវែងពណ៌ខ្មៅ ថ្នេរបង្កប់ ចង្កេះត មានភ្ជិតពីរ ហោប៉ៅបួន ( ខាងក្រោយពីរគ្មានគំរប នៅចំហៀងដេរបញ្ឆិតតាមថ្នេរខោ )

-ស្បែកជើងកខ្លីពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

-ឯកសណ្ឋានប្រយុទ្ធ ដូចទ័ពជើងគោក តែប៉េរ៉េពណ៌ខៀវទឹកសមុទ្រ ហើយកន្សែងរុំក (ហ្វូឡា) ពណ៌ខៀវទឹកសមុទ្រ ( ខៀវទឹកប៊ិច ) ។

ខ-<u>ឯកសណ្ឋានកងអាកាសចរភូមិន្ទ កម្ពុជា</u> :

គ្រប់ប្រភេទនៃឯកសណ្ឋាននិងគ្រប់បណ្តាថ្នាក់នាយទាហាន នាយទាហានរងនិង ពលទាហាន មានឯកសណ្ឋានដូចគ្នាជើងគោក តែឯកសណ្ឋានអាកាសចរភូមិន្ទកម្ពុជាត្រូវបានកំណត់ពណ៌ ដូចខាងក្រោម ៖

១-<u>ឯកសណ្ឋានលេខ ១</u> : អាវកុដស ពណ៌ស ខោពណ៌ខៀវក្រមៅនិងមួកកាសស្កេតពណ៌ខៀវក្រមៅជើងមួកពណ៌ក្របាក ។

២-<u>ឯកសណ្ឋានលេខ ២ លេខ ៣ និងលេខ ៤</u> : ពណ៌ខៀវក្រមៅ ស្បែកជើងពណ៌ខ្មៅដូចទ័ពជើងគោកដោយឡែកអាវសីមីក្នុងរបស់ឯកសណ្ឋានធំលេខ ២កាត់ដូចជើងគោក ពណ៌ផ្ទៃមេឃ ។ ហើយ

ឯកសណ្ឋានការងារមានមួយសំរាប់ អាវពណ៌ខៀវផ្ទៃមេឃ ខោពណ៌ខៀវក្រមៅ មួកបេរ៉េពណ៌ខៀវក្រមៅកាត់ដូចទ័ពជើងគោកនិងខ្សែក្រវាត់តូចពណ៌ទឹកប៊ិច ក្បាលលាតពណ៌មាស ។

៣-ឯកសណ្ឋានប្រយុទ្ធ ៖ ដូចទ័ពជើងគោក ប៉េរ៉េនិងកន្សែងរុំកពណ៌ខៀវ ( ខៀវផ្ទៃមេឃ ) ។

មាត្រា ៣ ._ ក្នុងមាត្រា៣ថ្មីនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតម្រូវដូចខាងក្រោម ៖

ត្រូវបានរៀបចំឯកសណ្ឋានត្រៃទ័ពនិងកងកិត្តិយសដូចខាងក្រោម ៖

ក-ឯកសណ្ឋានត្រៃទ័ព ៖

-ឯកសណ្ឋានត្រៃទ័ពមានពីរសំរាប់ មួយពណ៌ស មួយទៀតពណ៌ត្រែអ៊ី ម៉ូត រូបរាងឯកសណ្ឋាននិងមួកកាសស្តេតដូចឯកសណ្ឋានលេខ ២ តែមួកកាសស្តេតធ្វើតាមឋានៈដូចទ័ពជើងគោក ស្បែកជើងស្បែក កវែងពណ៌ខ្មៅ ខ្សែក្រវាត់ធំពណ៌ខ្មៅ ក្រវាត់ពីលើអាវ អាវសឺមីក្នុងពណ៌ត្រែអ៊ីខ្ចីមួយ ពណ៌សមួយ ខ្សែរយោលពណ៌មាសនិងកន្សែងរុំកពណ៌លឿង ស្រោមដៃពណ៌ស ។

ខ-ឯកសណ្ឋានកងកិត្តិយស ៖

១-ឯកសណ្ឋានមេបញ្ជាការកងកិត្តិយសនិងអ្នកកាន់ទង់ ៖ ត្រូវពាក់ឯកសណ្ឋានលេខ ២ របស់ទ័ពជើងគោកតាមឋានន្តរសក្តិជាក់ស្តែង ។ ចំពោះមេបញ្ជាការកងកិត្តិយសតាមពណ្ណផែន ជើង គោក នាវាចរ អាកាសចរ ត្រូវបានពាក់ឯកសណ្ឋានធំលេខ ២តាមឋានន្តរសក្តិជាក់ស្តែងនិងតាមប្រភេទ ទ័ព ។

២-ឯកសណ្ឋានកងកិត្តិយស ជើងគោក ៖ ឯកសណ្ឋានមានមួយសំរាប់ពណ៌ត្រែអ៊ីដូចត្រៃទ័ព តែខុសគ្នាកងកិត្តិយសជើងគោកពាក់មួកស៊ីកាសពណ៌ខ្មៅ កន្សែងរុំកពណ៌លឿង ។

៣-ឯកសណ្ឋានកងកិត្តិយស នាវាចរ ៖ ឯកសណ្ឋានពណ៌ស មួកស៊ីកាសពណ៌សនិងកន្សែងរុំកពណ៌ស ( កាត់ម៉ូតឯកសណ្ឋានលេខ ២ កងនាវាចរភូមិន្ទកម្ពុជា ) ។

៤-ឯកសណ្ឋានកងកិត្តិយស អាកាសចរ ៖ ឯកសណ្ឋានពណ៌ខៀវក្រមៅ មួកស៊ីកាសពណ៌ខៀវ កន្សែងរុំកពណ៌ផ្ទៃមេឃ កាត់ដូចឯកសណ្ឋានលេខ ២ កងអាកាសចរភូមិន្ទកម្ពុជា ។

៥-ឯកសណ្ឋានកងកិត្តិយស ដាវ ៖ ពាក់ឯកសណ្ឋានលេខ ១ ថ្នាក់អនុសេនិយ ប្រើដាវមានស្រោមពណ៌សខ្សែរយោលដាវពណ៌មាស ដងដាវឆ្លាក់រូបព្រហ្មមុខបួន ផ្លែដាវពណ៌ទឹកប្រាក់ ចង្កូនិងដងដាវក្បាច់ពណ៌មាស ។

មាត្រា ៤ ._ ក្នុងមាត្រា ៤ថ្មី នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រូវបានកែតំរូវដូចខាងក្រោម ៖

ត្រូវបានកំណត់អំពីរបៀបប្រើប្រាស់និងពាក់ឯកសណ្ឋាន ផ្លាកនានា នៃកងយោធពលខេមរភូមិន្ទ ដូចខាងក្រោម ៖

-ការស្លៀកពាក់ឯកសណ្ឋានគឺជាច្បាប់របស់កងយោធពលខេមរភូមិន្ទ ដែលនាយទាហាន នាយទាហានរង និងពលទាហានគ្រប់រូបត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់បំផុតមិនអាចខះបានឡើយ សំដៅធ្វើអោយយោធិន

គ្រប់រូបទូទាំងកងយោធពលខេមរភូមិន្ទបានឯកភាពគ្នា ។ ហើយការស្លៀកពាក់ឯកសណ្ឋានត្រូវអនុវត្តអោយបានត្រឹមត្រូវតាមការកំណត់នៃអនុក្រឹត្យនេះ មិនអនុញ្ញាតអោយយោធិនណាម្នាក់ស្លៀកពាក់ខុសពីការកំណត់ឡើយ ហើយការស្លៀកពាក់ឯកសណ្ឋានត្រូវពាក់សក្តិតាមឋានន្តរសក្តិរបស់ខ្លួន ព្រមទាំងផ្លាកសញ្ញា ផ្សេងៗដែលកងយោធពលខេមរភូមិន្ទបានកំណត់ ។

ការប្រើប្រាស់និងពាក់ឯកសណ្ឋាន ផ្លាកសញ្ញានានា :

១-ឯកសណ្ឋានធំលេខ ១ : ( អាវកុដ ស )

-ឯកសណ្ឋានធំលេខ ១ សំរាប់ពាក់ក្នុងពិធីចូលគ្រាព្រះបរមរាជវាំងនិងព្រះរាជពិធីដូចជា : ច្រត់ព្រះនង្គ័ល អុំទូក បុណ្យឯករាជ្យជាតិ ។ល។

-ស្លៀកពាក់ឯកសណ្ឋានធំ អាវកុដស ខោពណ៌ក្រមៅ ឆ្នូតក្រហម មួកកាសស្កេតខ្មៅ មានរូបព្រះសង្ការស្បែកជើងប្លុបស្បែក កខ្លិពណ៌ខ្មៅ ស្រោមជើងខ្មៅ ពាក់សក្តិលើស្មាដែលមានផ្ទៃហ្លួងសក្តិក្រណាត់កាំម្ចីពណ៌មាស ពាក់ខ្សែរយោលលើស្មាស្តាំ កន្ទុយខ្សែចុតឡេវអាវទី២ និងពាក់គ្រឿងឥស្សរិយយសនៅខាងឆ្វេង ( បើមាន ) ហើយស្រោមដៃតាមពិធីការកំណត់ ។ ចំពោះផ្លាកឈ្មោះ រូបហនុមាននិងសញ្ញាប្រភេទទ័ពនៅកអាវ ឬ សញ្ញាផ្សេងៗទៀតមិនត្រូវពាក់ជាមួយឯកសណ្ឋានធំលេខ ១ នេះឡើយ ។

-ចំពោះកងនាវាចរនិងអាកាសចរត្រូវពាក់ឯកសណ្ឋានធំលេខ១របស់ខ្លួន របៀបស្លៀកពាក់និងពាក់សំភារៈរួមផ្សំដូចទ័ពជើងគោកដែរ ។

២-ឯកសណ្ឋានធំលេខ ២ : ( អាវភ៏រ )

-ឯកសណ្ឋានធំលេខ ២ នេះពាក់សំរាប់ចូលរួមក្នុងពិធីការជាតិនិងអន្តរជាតិធំៗ ( តាមការកំណត់របស់ពិធីការ ) ព្រមទាំងការចេញទៅបំពេញបេសកកម្មក្រៅប្រទេស ។

-ស្លៀកពាក់ឯកសណ្ឋានធំលេខ ២ ពាក់អាវស៊ីមីពណ៌ក្រែអ៊ីខ្ចីទាំងពេលថ្ងៃ យប់និងបុណ្យសពក្រវាត់កពណ៌ខ្មៅ ខោជើងវែងពណ៌ក្រែអ៊ី មួកកាសស្កេតពណ៌ក្រែអ៊ី មានរូបព្រះសង្ការ ស្បែកជើងកខ្លីពណ៌ខ្មៅស្រោមជើងពណ៌ខ្មៅ ពាក់សក្តិស្មា ផ្ទៃហ្លួងពណ៌ខ្មៅ ក្បាលស្រួច ពាក់ខ្សែរយោលលើស្មាស្តាំ កន្ទុយខ្សែពាក់ឡេវអាវទី១ ពាក់សញ្ញានៅកអាវ ពាក់ផ្លាកឈ្មោះនៅលើហោប៉ៅអាវស្តាំ បន្តោងរូបហនុមាននៅលើហោប៉ៅស្តាំ ពាក់ស្រោមដៃតាមពិធីការកំណត់និងគ្រឿងឥស្សរិយយសនៅខាងឆ្វេង ( លក្ខណៈចាំបាច់គួរពាក់មេដៃនិងលក្ខណៈធម្មតាពាក់ក្បាលមេដៃ ) ។ ចំពោះការចេញទៅបំពេញបេសកកម្មក្រៅប្រទេសមិនបាច់ពាក់ខ្សែរយោលឡើយ ។

-ចំពោះកងនាវាចរនិងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានធំលេខ២ របស់ខ្លួននិងពាក់គ្រឿងរួមផ្សំផ្សេងទៀតព្រមទាំងរបៀបពាក់ដូចទ័ពជើងគោកដែរ តែកងនាវាចរត្រូវស្លៀកពាក់ឯកសណ្ឋានធំលេខ ២ ពណ៌ខ្មៅសំរាប់ពាក់ពេលបំពេញបេសកកម្មនៅក្រៅប្រទេសនារដូវរងារ ។ ឯកងអាកាសចរឆ័ត្រយោងត្រូវពាក់សញ្ញារបស់ខ្លួនលើផ្លាកឈ្មោះថែមទៀត ។ ការចេញទៅក្រៅប្រទេសមិនបានពាក់ខ្សែរយោលឡើយ ។

-ចំពោះនៅដៃអាវមិនបានពាក់ផ្លាកកងយោធពលខេមរភូមិន្ទនិងផ្លាកអ្វីទៀតឡើយ ។

៣-ឯកសណ្ឋានលេខ ៣ : ( សាហារីយែន )

-ឯកសណ្ឋាននេះពាក់សំរាប់ចូលរួមក្នុងពិធីការជាតិនិងអន្តរជាតិដែលមានលក្ខណៈធម្មតា និងពិធីការ ផ្សេងៗដូចជា : ទទួលភ្ញៀវជាតិនិងអន្តរជាតិ ពិធីបិទវគ្គ បើកវគ្គ ។ល។

-ការស្លៀកពាក់ : ពាក់អាវគកបើកវែង នៅដៃអាវ ... ពលខេមរភូមិន្ទ ខោ ជើងវែង ពណ៌ត្រួតអ៊ី ម្កុកគាតស្លុតពណ៌ត្រួតអ៊ី មានរូបព្រះសង្ហារ ស្បែកជើង... ក ខ្លី ពណ៌ខ្មៅ ពាក់សញ្ញាក ពាក់សក្តិស្មាដែលមានផ្ទៃប្រុងសក្តិពណ៌ខ្មៅ ក្បាលស្រួច ពាក់ផ្លាកឈ្មោះ សញ្ញាពានមុំអាននិងក្បាលមេដៃ ( បើមាន ) ។

-ចំពោះកងនាវាចរនិងអាកាសចរត្រូវស្លៀកពាក់ឯកសណ្ឋានលេខ ៣របស់ខ្លួន ហើយពាក់គ្រឿង រួមផ្សំផ្សេងទៀតនិងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរត័ត្រូវបោកង ឬ កងឯកភាព ដែលមានផ្លាក សញ្ញាលើហោប៉ៅស្តាំលើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

៤-<u>ឯកសណ្ឋានលេខ ៤</u> : ( ឯកសណ្ឋានការងារ )

-ឯកសណ្ឋាននេះសំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយនិងទំនាក់ទំនងការងារ ធម្មតា ។

-<u>ការស្លៀកពាក់</u> : ពាក់អាវដៃខ្លីពណ៌ត្រួតអ៊ី នៅដៃអាវស្តាំដាក់ផ្លាកកងពលខេមរភូមិន្ទ និង នៅដៃអាវឆ្វេងពាក់ផ្លាកកងឯកភាព ( បើមាន ) ខោជើងវែងពណ៌ត្រួតអ៊ី ខ្សែក្រវាត់តូចពណ៌ត្រួតអ៊ី ម្កុកពាសេ ពណ៌ត្រួតអ៊ីមានរូបព្រះសង្ហារនៅខាងមុខផ្នែកខាងស្តាំនិងមានសញ្ញាសក្តិនៅខាងមុខផ្នែកខាងឆ្វេង ស្បែកជើង ស្បែក កខ្លីពណ៌ខ្មៅនិងស្រោមជើងខ្មៅ ពាក់សញ្ញាប្រភេទទ័ពនៅកអាវ ផ្លាកឈ្មោះនៅលើហោប៉ៅស្តាំ បានុមាន ពាក់នៅឡើវហោប៉ៅស្តាំ សក្តិនៅលើស្មាដែលមានប្លង់សក្តិខ្មៅ ក្បាលស្រួចនិងពាក់ក្បាលមេដៃ ( បើមាន ) អាវ ជានិច្ចកាលត្រូវដាក់ក្នុងខោ ។

-ចំពោះកងនាវាចរនិងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានការងារតាមការកំណត់ខាងលើ ហើយពាក់គ្រឿងរួមផ្សំផ្សេងទៀតនិងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរនិងបណ្តាកងឯកភាព ដែលមានសញ្ញាលើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

៥-ឯកសណ្ឋានលេខ ៥ : ( ឯកសណ្ឋានប្រយុទ្ធ )

-ឯកសណ្ឋានប្រយុទ្ធនេះពាក់សំរាប់ចេញប្រតិបត្តិការឬបេសកកម្មក្រៅបន្ទាយ ចំពោះនៅក្នុង បន្ទាយអាចពាក់បាន តែត្រូវមានការកំណត់ពីមេបញ្ជាការហើយបានឯកភាពគ្នាទូទាំងកងឯកភាព ។

-<u>ការស្លៀកពាក់</u> : ពាក់អាវដៃវែង ហោប៉ៅបួន អាចមូរដៃបាន តែត្រូវឯកភាពគ្នា ( បើសិនជាមូរ ត្រូវមូរទាំងអស់គ្នា ) នៅដើមដៃអាវស្តាំដាក់ផ្លាកកងពលខេមរភូមិន្ទនិងដើមដៃអាវឆ្វេងដាក់ផ្លាកកងឯកភាព (បើមាន) ខោជើងវែងមានហោប៉ៅប្រាំមួយ ជើងខោចងខ្សែ ពាក់មួកល្បៀកកីមានរូបព្រះសង្ហារឬពាក់បេរ៉េដាក់រូប ព្រះសង្ហារស្តាំទាញបញ្ឆិតមកឆ្វេង នៅពេលចេញប្រតិបត្តិការសឹកអាចពាក់មួកដែក ( ចំពោះការពាក់មួកគ្រប់ ប្រភេទត្រូវអនុវត្តតាមការកំណត់របស់កងឯកភាពនីមួយៗ បើសិនពាក់មួកណាត្រូវពាក់មួកនោះអោយបានឯកភាព គ្នាទាំងអស់ ហើយហាមស្លៀកពាក់ដោយគ្មានមួក ពាក់សក្តិប្រយុទ្ធកអាវខាងឆ្វេង នៅកអាវស្តាំពាក់ផ្លាកសញ្ញា

ប្រភេទទ័ពឬទ័ពជំនាញនៅកអាវ ( អាចប៉ាក់ដេរភ្ជាប់កអាវពណ៌មាស ) ផ្លាកឈ្មោះត្រូវដេរភ្ជាប់អាវលើហោប៉ៅស្តាំ អក្សរពណ៌ខ្មៅ ពាក់ខ្សែរុំ អាចមិនពាក់បានតាមការកំណត់របស់កងឯកភាព ពាក់សង់ទ្រ៊ុង ( ខ្សែក្រវាត់ធំ ) និងពាក់ស្បែកជើងកវែងពណ៌ខ្មៅឬស្បែកជើងអែបប្រកកវែង ។

-ចំពោះកងអាកាសចរនិងកងនាវាចរពាក់ឯកសណ្ឋានប្រពៃណីរបស់ខ្លួន ហើយពាក់គ្រឿងរួមផ្សំនិងរបៀបប្រើប្រាស់ដូចទ័ពជើងគោក ។ តែកងអាកាសចរនិងបណ្តាកងឯកភាពដែលមានសញ្ញាលើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវប៉ាក់ភ្ជាប់អាវ រូបសញ្ញាពណ៌មាស ។

៦-<u>ឯកសណ្ឋានបច្ចេកទេសជំនាញ</u> :

-ការស្លៀកពាក់ឯកសណ្ឋានបច្ចេកទេសជំនាញដែលបានកំណត់ខាងលើ ចំពោះបណ្តាកងឯកភាពដែលមានឯកសណ្ឋាននេះត្រូវពាក់នៅពេលធ្វើការបច្ចេកទេសជាមួយគ្រឿងចក្រនិងឧបករណ៍បច្ចេកទេស ពេលចប់ត្រូវផ្លាស់ប្តូរវិញ មិនបានពាក់ឯកសណ្ឋាននេះដើរចេញក្រៅកងឯកភាពឬក្រៅម៉ោងធ្វើការបច្ចេកទេសឡើយ លើកលែងតែអ្នកបើកបរយន្តហោះ ។ ហើយឯកសណ្ឋាននេះមិនចាំបាច់ពាក់សក្តិ សញ្ញាផ្សេងៗរបស់កងយោធពលខេមរភូមិន្ទទេ ។ តែអ្នកបើកបរយន្តហោះត្រូវដាក់រាល់សញ្ញាដែលមាន ( ប៉ាក់ភ្ជាប់ ) និងសក្តិ ។

៧-ចំពោះទង់កងយោធពលខេមរភូមិន្ទគ្រប់បណ្តាថ្នាក់ត្រូវរក្សាទុកកន្លែងដែលមានសុវត្ថិភាពថ្លៃថ្នូរ និងការពារហ្មត់ចត់បំផុត ។ ក្នុងរយៈពេលមួយឆមាសត្រូវប្រារព្ធពិធីសច្ចាប្រណិធានចំពោះមុខទង់របស់ខ្លួនម្តង ។ ពេលយកចេញមកក្រៅត្រូវធ្វើអោយបានត្រឹមត្រូវតាមភូមិបទយោធា ។

-នាយទាហាន នាយទាហានរងនិងពលទាហានទូទាំងកងយោធពលខេមរភូមិន្ទ ត្រូវស្លៀកពាក់ឯកសណ្ឋានតាមការកំណត់ខាងលើក្នុងអនុក្រឹត្យនេះ ។ ចំពោះបុគ្គលណាម្នាក់ដែលមិនបានស្លៀកពាក់អោយបានគ្រប់គ្រាន់តាមការកំណត់នេះត្រូវចាត់ទុកជាការល្មើសនឹងវិន័យរបស់កងយោធពលខេមរភូមិន្ទ ។

-ចំពោះការផលិតត្រូវធ្វើតាមការកំណត់របស់អនុក្រឹត្យនេះ និងមានគុណភាពខ្ពស់ ។

-ក្នុងករណីមានជំនួយពីបណ្តាប្រទេសជាមិត្ត អំពីឯកសណ្ឋានឬយោធបរិក្ខារផ្សេងៗ ហើយខុសពីការកំណត់នេះ អាចប្រើប្រាស់បានលុះត្រាតែមានការអនុញ្ញាតជាផ្លូវការពីក្រសួងការពារជាតិនិងអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៥ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា
ស៊ីសុវត្ថិ សិរីរត្ន ទៀ បាញ់

# អនុក្រឹត្យលេខ ៤៨ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ .**_ ត្រូវបានតែងតាំងលោក **គឹម ម៉ុនថាន** ជា នាយករង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ .**_ បទបញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៨៩ អនក្រ.តត**

**ស្តីពីការបំពាក់ឋានន្តរសក្តិនាយនគរបាលជាតិ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០២/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិ ដូចមានរាយនាមខាងក្រោម ៖

១-លោក គួច ម៉ុនលាត អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក នៃក្រសួងមហាផ្ទៃ ។

២-លោក ស្វា ប្រុយុទ្ធ អនុប្រធានអធិការដ្ឋានកិច្ចការនគរបាល នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៩០ អនក្រ.តត**

**ស្តីពីការបញ្ជូនមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌដើមវិញ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០២/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបញ្ជូនលោក ត្រឹ ស៊ូ អតីតអភិបាលរងខេត្តស្ទឹងត្រែង ឲ្យទៅកាន់ក្របខ័ណ្ឌក្រសួងការពារជាតិវិញ ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៩១ អនក្រ.តត

## ស្តីពីការដូនមេដាយការងារ

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០២/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាសការងារ ជូននាយទាហាន ០៣រូប នៃអធិការកិច្ចកងទ័ពជើងគោក ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ដោះស្រាយវិវាទ រវាងកងទ័ពនិងប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម :

១-លោក វរសេនីយឯក ម៉ៅ ញ៉ នាយរងអធិការកិច្ចកងទ័ពជើងគោក

២-លោកស្រីវរសេនីយត្រី ចំន្ទ មុនី នាយផ្នែកប្រព័ន្ធច្បាប់ និងវិវាទ

៣-លោកវរសេនីយត្រី អ៊ិន នរិន្ទ នាយរងផ្នែកយោធភូមិភាគ

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៩២ អនក្រ.តត**

**ស្តីពីការជូនមេដាយការងារ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០២/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយការងារ តាមលំដាប់ថ្នាក់ជូនអង្គភាព និងនាយទាហាន ក្នុងកងឯកភាពយោធភូមិភាគទី៣ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក-មេដាយមាសការងារ :

-ចំពោះអង្គភាព :

១-យោធភូមិភាគទី ៣

២-កងពលតូចលេខ ៤៤

៣-វរសេនាធំលេខ ៨៣

៤-វរសេនាធំលេខ ៣៧

៥-សាលាពលទាហានទី៣

៦-តំបន់ប្រតិបត្តិការសឹករង កំពង់ស្ពឺ

៧-តំបន់ប្រតិបត្តិការសឹករង តាកែវ

៨-តំបន់ប្រតិបត្តិការសឹករង កំពត

៩-តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

១០-តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

១១-តំបន់ប្រតិបត្តិការសឹករង កោះកុង

-ចំពោះបុគ្គល :

| | | |
|---|---|---|
| ១-ឧត្តមសេនីយឯក | សឺរិន្ទ ឌី | មេបញ្ជាការរងកងទ័ព ជើងគោក |
| ២-ឧត្តមសេនីយទោ | កែវ សាមួន | មេបញ្ជាការយោធភូមិភាគទី ៣ |
| ៣-ឧត្តមសេនីយត្រី | ម៉ិន សំ | មេបញ្ជាការរងយោធភូមិភាគទី ៣ |
| ៤-ឧត្តមសេនីយត្រី | ខឹម ជាសាឡឿន | មេបញ្ជាការរងយោធភូមិភាគទី ៣ |
| ៥-ឧត្តមសេនីយត្រី | កែវ ពន្យ | មេបញ្ជាការរងយោធភូមិភាគទី ៣ |
| ៦-ឧត្តមសេនីយត្រី | គង់ ម៉ុនថន | មេបញ្ជាការរងនិងជានាយសេនាធិការយោធភូមិភាគទី ៣ |
| ៧-វរសេនីយឯក | មិន នឹម | នាយរងសេនាធិការយោធភូមិភាគទី៣ |
| ៨-វរសេនីយឯក | មិត្ត ម៉ុនរ័ត្ន | នាយរងសេនាធិការយោធភូមិភាគទី ៣ |
| ៩-វរសេនីយឯក | ស៊ាម ឃី | នាយរងសេនាធិការយោធភូមិភាគទី ៣ |
| ១០-វរសេនីយឯក | ហួយ ឆវ័ន្ត | នាយរងសេនាធិការយោធភូមិភាគទី ៣ |
| ១១-វរសេនីយឯក | សុត្រ ស៊ុយ | នាយរងសេនាធិការយោធភូមិភាគទី ៣ |
| ១២-វរសេនីយឯក | ឡុង ខេង | នាយរងសេនាធិការយោធភូមិភាគទី ៣ |
| ១៣-វរសេនីយឯក | ហ៊ិច ស្រេង | នាយរងសេនាធិការយោធភូមិភាគទី ៣ |
| ១៤-វរសេនីយឯក | នាម សៀង | នាយរងសេនាធិការយោធភូមិភាគទី ៣ |
| ១៥-វរសេនីយឯក | ស្រ៊ិន សាឡឿន | មេបញ្ជាការកងពលតូចលេខ ៤៤ |
| ១៦-វរសេនីយឯក | ខឹម សន | មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករង ខេត្តកំពង់ស្ពឺ |

១៧-វរសេនីយឯក គង់ សំអឿន មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករង ខេត្តតាកែវ
១៨-វរសេនីយឯក គាន់ ណាំង មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករង ខេត្តកោះកុង
១៩-វរសេនីយឯក ឆេ ខា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ
២០-វរសេនីយឯក ជន សុផល មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប
២១-វរសេនីយឯក អ៊ុង ចណ្ណារិទ្ធ មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករង ខេត្តកំពត
២២-វរសេនីយឯក ស្វាយ ផុនមុន្នី អតីតអភិបាលស្រុកកំពង់ត្រាច ខេត្តកំពតយោធភូមិភាគទី ៣
២៣-វរសេនីយឯក ខែម ប៉ាន់ អភិបាលស្រុកជុំគិរី ខេត្តកំពត

ខ-មេដាយប្រាក់ការងារ :

១-វរសេនីយ៍ទោ ស ស៊ីនឿន នាយការិយាល័យទី ១ យោធភូមិភាគទី ៣
២-វរសេនីយ៍ទោ ម៉ៃ ម៉ៅ នាយការិយាល័យទី ២ យោធភូមិភាគទី ៣
៣-វរសេនីយ៍ទោ ថាច់ មុណាវ៉េត នាយការិយាល័យទី ៣ យោធភូមិភាគទី ៣
៤-វរសេនីយ៍ទោ លឹម សុផន នាយការិយាល័យទី ៤ យោធភូមិភាគទី ៣
៥-វរសេនីយ៍ទោ អ៊ិន ជាព័ត៌ នាយការិយាល័យទី ៥ យោធភូមិភាគទី ៣
៦-វរសេនីយ៍ទោ ឡាយ លឹមស្រួយ នាយការិយាល័យហិរញ្ញ យោធភូមិភាគទី ៣
៧-វរសេនីយ៍ទោ សំ សំអាត នាយការិយាល័យយោធាតំបន់ យោធភូមិភាគទី ៣
៨-វរសេនីយ៍ទោ សេង សារី នាយផ្នែកហិរញ្ញវត្ថុ យោធភូមិភាគទី ៣
៩-វរសេនីយ៍ទោ នួន ណម នាយកសាលាពលទាហានទី៣ យោធភូមិភាគទី ៣
១០-វរសេនីយ៍ទោ គាន់ សេង នាយកតំបន់អភិវឌ្ឍន៍ យោធភូមិភាគទី ៣
១១-វរសេនីយ៍ទោ សារិទ្ធ វ៉ាង មេបញ្ជាការ វរសេនាធំលេខ ៣៧
១២-វរសេនីយ៍ទោ ម៉ុង ថា មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ស្ពឺ
១៣-វរសេនីយ៍ទោ ឌុក ទ៉ាន់ឡើន មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ស្ពឺ
១៤-វរសេនីយ៍ទោ ម៉ូ សុខគីម មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ស្ពឺ
១៥-វរសេនីយ៍ទោ និន សំអាត មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ស្ពឺ
១៦-វរសេនីយ៍ទោ សារិទ្ធ សុជាត មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ស្ពឺ
១៧-វរសេនីយទោ ម៉ៅ សឿន មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ស្ពឺ
១៨-វរសេនីយ៍ទោ ឈឹម ម៉ុនធឿន មេបញ្ជាការរងនិងជានាយសេនាធិការតំបន់ប្រតិបត្តិការសឹករង ខេត្តកំពង់ស្ពឺ
១៩-វរសេនីយទោ មាស ច័ន្ទគីរី មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពត
២០-វរសេនីយទោ យឹម ម៉ុនធឿន មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកំពត
២១-វរសេនីយទោ អឿ សឿន មេបញ្ជាការរងនិងជាសេនាធិការតំបន់ប្រតិបត្តិការសឹករងខេត្តកំពត

២២-វរសេនីយទោ នួន ផន មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងក្រុងកែប

២៣-វរសេនីយទោ ឈឹម ខ្មៅ មេបញ្ជាការរងនិងជាសេនាធិការតំបន់ប្រតិបត្តិការសឹករងក្រុងកែប

២៤-វរសេនីយ៍ទោ ម្សៀច ហ៊ាន់ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

២៥-វរសេនីយ៍ទោ ឡាំ ម៉េន មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

២៦-វរសេនីយទោ ខៀវ គុណ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

២៧-វរសេនីយទោ គង់ សំណាង មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

២៨-វរសេនីយទោ ស៊ាង ចាន់ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

២៩-វរសេនីយទោ រស់ ខៀត មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

៣០-វរសេនីយ៍ទោ ព្រំ សាវ៉ុន មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

៣១-វរសេនីយ៍ទោ សុខ រំដួល មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

៣២-វរសេនីយ៍ទោ ម៉ម សុខា មេបញ្ជាការរងនិងជានាយសេនាធិការតំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

៣៣-វរសេនីយ៍ទោ សិរ កាត់តើ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង កោះកុង

៣៤-វរសេនីយ៍ទោ ចុង ម៉ន មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង កោះកុង

៣៥-វរសេនីយទោ សោម សាមិទ្ធ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង កោះកុង

៣៦-វរសេនីយទោ ហែម ជាវ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង កោះកុង

៣៧-វរសេនីយទោ យន្ត មីន មេបញ្ជាការរងនិងជាសេនាធិការ តំបន់ប្រតិបត្តិការសឹករង កោះកុង

៣៨-វរសេនីយទោ សាយ សារុន មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង តាកែវ

៣៩-វរសេនីយទោ ឈឹម ភាធីម មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង តាកែវ

៤០-វរសេនីយទោ ពិន មុន្នី មេបញ្ជាការរងនិងជានាយសេនាធិការ តំបន់ប្រតិបត្តិការសឹករង តាកែវ

៤១-វរសេនីយទោ អ៊ុច ប៊ុន មេបញ្ជាការ វរសេនាធំ លេខ ៨៣

៤២-វរសេនីយទោ មុំ សំ មេបញ្ជាការរង កងពលតូច លេខ ៤៤

៤៣-វរសេនីយទោ គោគ ចន្ថា មេបញ្ជាការរង កងពលតូច លេខ ៤៤

៤៤-វរសេនីយទោ ម៉ៅញ ឈុនឌី មេបញ្ជាការរង កងពលតូច លេខ ៤៤

៤៥-វរសេនីយទោ មាស សុខ មេបញ្ជាការរង កងពលតូច លេខ ៤៤

៤៦-វរសេនីយទោ ឈន ឡោ មេបញ្ជាការរង កងពលតូច លេខ ៤៤

៤៧-វរសេនីយទោ វណ្ណ ស៊ីន មេបញ្ជាការរង កងពលតូច លេខ ៤៤

៤៨-វរសេនីយទោ លិន ឆាន់ មេបញ្ជាការរង កងពលតូច លេខ ៤៤

៤៩-វរសេនីយទោ ជុំ សម្បត្តិ មេបញ្ជាការរង កងពលតូច លេខ ៤៤

៥០-វរសេនីយទោ គង់ ឆេងខន មេបញ្ជាការរងនិងជានាយសេនាធិការ កងពលតូច លេខ ៤៤

៥១-វរសេនីយត្រី យ៉ាន សំបូរ នាយរងការិយាល័យទី២ យោធភូមិភាគ ៣
៥២-វរសេនីយត្រី សូ ពិន នាយរងការិយាល័យទី ២ យោធភូមិភាគ ៣
៥៣-វរសេនីយត្រី អ៊ិត ម៉ុនធឿន នាយរងការិយាល័យទី ២ យោធភូមិភាគ ៣
៥៤-វរសេនីយត្រី មាស សាធឿន នាយឯកទេសបញ្ជូនសារ យោធភូមិភាគ ៣
៥៥-វរសេនីយត្រី ចាន់ សំបូរ នាយឯកទេសបច្ចេកទេស យោធភូមិភាគ ៣
៥៦-វរសេនីយត្រី ម៉ៅ សាទុធ នាយឯកទេសរថក្រោះ យោធភូមិភាគ ៣
៥៧-វរសេនីយត្រី រស់ សារ៉េត នាយរងលេខាធិការដ្ឋាន យោធភូមិភាគ ៣
៥៨-វរសេនីយត្រី ស៊ុន ស៊ាត នាយរងការិយាល័យអភិវឌ្ឍន៍យោធភូមិភាគ ៣
៥៩-វរសេនីយត្រី ជិន ហៀង នាយរងការិយាល័យទី៥ យោធភូមិភាគ ៣
៦០-វរសេនីយត្រី ម៉ៅ ផលរិន នាយរងផ្នែកហិរញ្ញវត្ថុ យោធភូមិភាគ ៣
៦១-វរសេនីយត្រី យ៉េម ទិបុល នាយរងផ្នែកហិរញ្ញវត្ថុ យោធភូមិភាគ ៣
៦២-វរសេនីយត្រី ជា យឿន នាយរងការិយាល័យយោធាតំបន់ យោធភូមិភាគ ៣
៦៣-វរសេនីយត្រី អ៊ិន សារ៉ាក់ នាយរងការិយាល័យយោធាតំបន់ យោធភូមិភាគ ៣
៦៤-វរសេនីយត្រី ងឹង ផល្លី នាយរងការិយាល័យយោធាតំបន់ យោធភូមិភាគ ៣
៦៥-វរសេនីយត្រី អ៊ុច ចាន់នី នាយរងការិយាល័យទី ១ យោធភូមិភាគ ៣
៦៦-វរសេនីយត្រី ជាន ហង្ស នាយរងការិយាល័យទី ១ យោធភូមិភាគ ៣
៦៧-វរសេនីយត្រី ផុន ឆាម នាយរងការិយាល័យទី ១ យោធភូមិភាគ ៣
៦៨-វរសេនីយត្រី មាស សារី នាយរងការិយាល័យទី ១ យោធភូមិភាគ ៣
៦៩-វរសេនីយត្រី ប៉ាក់ សិទ្ធិគុណ នាយរងការិយាល័យទី ៤ យោធភូមិភាគ ៣
៧០-វរសេនីយត្រី អ៊ី សុខ នាយរងការិយាល័យទី ៤ យោធភូមិភាគ ៣
៧១-វរសេនីយត្រី ជូ ខួនហេង នាយរងការិយាល័យទី ៤ យោធភូមិភាគ ៣
៧២-វរសេនីយត្រី ម៉ឹម ឈៀង នាយការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគ ៣
៧៣-វរសេនីយត្រី ស្រី ទុន្នី នាយលេខាធិការដ្ឋាន យោធភូមិភាគ ៣
៧៤-វរសេនីយត្រី សៅ ចន្ថន នាយឯកទេសកាំភ្លើងធំ យោធភូមិភាគ ៣
៧៥-វរសេនីយត្រី ហេង គឹមម៉េង នាយឯកទេសសុខាភិបាល យោធភូមិភាគ ៣
៧៦-វរសេនីយត្រី ជឹម ភាឈា នាយកមន្ទីរពេទ្យ យោធភូមិភាគ ៣
៧៧-វរសេនីយត្រី អ៊ួន សារុំ នាយឯកទេសវិស្វកម្ម យោធភូមិភាគ ៣
៧៨-វរសេនីយត្រី ជិន សារ៉េត នាយឯកទេសស៊ើបការ យោធភូមិភាគ ៣
៧៩-វរសេនីយត្រី អ៊ឹម សុផាត នាយរងការិយាល័យទី ៣ យោធភូមិភាគ ៣
៨០-វរសេនីយត្រី កែវ សុផល នាយរងការិយាល័យទី ៣ យោធភូមិភាគ ៣

៨១-វរសេនីយ៍ត្រី ណើយ វ៉ាត នាយករងសាលាពលទាហានទី ៣ យោធភូមិភាគ ៣

៨២-វរសេនីយត្រី ឡាំ សម្បូណ៌ នាយករងសាលាពលទាហានទី ៣ យោធភូមិភាគ ៣

៨៣-វរសេនីយត្រី ជី គឹមហាក់ នាយករងសាលាពលទាហានទី៣ យោធភូមិភាគ ៣

៨៤-វរសេនីយត្រី កង សំអួន នាយករងសាលាពលទាហានទី ៣ យោធភូមិភាគ ៣

៨៥-វរសេនីយត្រី យស ស៊ីផុន នាយករងតំបន់អភិវឌ្ឍន៍ យោធភូមិភាគ ៣

៨៦-វរសេនីយត្រី ស៊ីន មឿន នាយករងតំបន់អភិវឌ្ឍន៍ យោធភូមិភាគ ៣

៨៧-វរសេនីយត្រី ម៉ែន សុផាន នាយករងតំបន់អភិវឌ្ឍន៍ យោធភូមិភាគ ៣

៨៨-វរសេនីយ៍ត្រី ឡេង សារី មេបញ្ជាការរង វរសេនាធំលេខ ៣៧

៨៩-វរសេនីយ៍ត្រី សាយ ទ័រ មេបញ្ជាការរង វរសេនាធំលេខ ៣៧

៩០-វរសេនីយ៍ត្រី ឡាយ មឿន មេបញ្ជាការរង វរសេនាធំលេខ ៣៧

៩១-វរសេនីយត្រី ខុម ខុន មេបញ្ជាការរង និងនាយសេនាធិការ វរសេនាធំលេខ ៣៧

៩២-វរសេនីយត្រី ឌី លាត នាយរងការិយាល័យយោធាតំបន់ យោធភូមិភាគ ៣

៩៣-វរសេនីយត្រី អ៊ុំ សង នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពង់ស្ពឺ

៩៤-វរសេនីយត្រី ម៉ីុង ជុំ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពង់ស្ពឺ

៩៥-វរសេនីយត្រី ឈុំ ទិសាល នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពង់ស្ពឺ

៩៦-វរសេនីយត្រី ហ៊ួ ឆៀង នាយរងសេនាធិការ កងពលតូចលេខ ៥៥

៩៧-វរសេនីយត្រី ម៉ម មេត នាយរងសេនាធិការ កងពលតូចលេខ ៥៥

៩៨-វរសេនីយត្រី តក ឈន នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពត

៩៩-វរសេនីយត្រី សេង សេរីបុត្រ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពត

១០០-វរសេនីយត្រី ថាន់ គឹមស៊ួន នាយរងសេនាធិការ តំប់ប្រតិបត្តិការសឹករង កំពត

១០១-វរសេនីយត្រី ហែម ពុធ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពត

១០២-វរសេនីយត្រី ធុក ម៉ិនថន នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពត

១០៣-វរសេនីយត្រី អ៊ុក សំបូរ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កំពត

១០៤-វរសេនីយត្រី ម៉ែន សំបូរ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

១០៥-វរសេនីយត្រី ហោ សែត នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

១០៦-វរសេនីយត្រី តែ សារឹម នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

១០៧-វរសេនីយត្រី ឃួន សុវណ្ណ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប

១០៨-វរសេនីយត្រី សុខ សាគល នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

១០៩-វរសេនីយត្រី ឈឿន ចិន្ត្រា នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

១១០-វរសេនីយត្រី ចុង សុក នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

១១១-វរសេនីយ៍ត្រី អ៊ុក វណ្ណា នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ
១១២-វរសេនីយ៍ត្រី រស់ ឫទ្ធី នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ
១១៣-វរសេនី... នឹម នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ
១១៤-វរសេនីយ៍ត្រី ចិន សុវណ្ណ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ
១១៥-វរសេនីយ៍ត្រី ឡែ ឆិម នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប
១១៦-វរសេនីយ៍ត្រី សុខ សុវត្ថិធុំម នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង កោះកុង
១១៧-វរសេនីយ៍ត្រី ឆេព វណ្ណី នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប
១១៨-វរសេនីយ៍ត្រី គ្រួច ម៉ូរី នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងកែប
១១៩-វរសេនីយ៍ត្រី សេង សារឿន នាយរងការិយាល័យទី៥ យោធភូមិភាគ ៣
១២០-វរសេនីយ៍ត្រី អ៊ឹម អាង នាយរងការិយាល័យទី ៥ យោធភូមិភាគ ៣
១២១-វរសេនីយ៍ត្រី ពៅ ស៊ុំ នាយរងការិយាល័យទី ៥ យោធភូមិភាគ ៣
១២២-វរសេនីយ៍ត្រី សុខ សុន នាយរងការិយាល័យហ្វឹកហ្វឺន យោធភូមិភាគ ៣
១២៣-វរសេនីយ៍ត្រី អ៊ុក សុវណ្ណា នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង តាកែវ
១២៤-វរសេនីយ៍ត្រី នួច លន់ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង តាកែវ
១២៥-វរសេនីយ៍ត្រី ម៉ុច គន់ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង តាកែវ
១២៦-វរសេនីយ៍ត្រី នាង នួន មេបញ្ជាការរង វរសេនាធំលេខ ៨៣
១២៧-វរសេនីយ៍ត្រី សំ សោម មេបញ្ជាការរង វរសេនាធំលេខ ៨៣
១២៨-វរសេនីយ៍ត្រី សួន យឺត មេបញ្ជាការរង វរសេនាធំលេខ ៨៣
១២៩-វរសេនីយ៍ត្រី មាស ជីម នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣០-វរសេនីយ៍ត្រី សាន សាម៉ន នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣១-វរសេនីយ៍ត្រី ហង្ស លឹម នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣២-វរសេនីយ៍ត្រី គង់ ឆ្នាំ នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣៣-វរសេនីយ៍ត្រី ស៊ឹម ថេង នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣៤-វរសេនីយ៍ត្រី ស្មៀង ធឿន នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣៥-វរសេនីយ៍ត្រី សំ ម៉ុន នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣៦-វរសេនីយ៍ត្រី ដួង ណាក នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣៧-វរសេនីយ៍ត្រី សៅ ម៉ុង នាយរងសេនាធិការ កងពលតូចលេខ ៥៥
១៣៨-វរសេនីយ៍ត្រី ម៉ែន ឆាន់ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

**គ-មេដាយសិរីវឌ្ឍនភាពមាស :**

១-អនុសេនីយ៍ឯក សែ ធី នាយការិយាល័យទី ១ តំបន់ប្រតិបត្តិការសឹករង កំពត

២-អនុសេនីយ៍ឯក គុល ហេង នាយការិយាល័យទី ៤ តំបន់ប្រតិបត្តិការសឹករង កំពត
៣-អនុសេនីយ៍ឯក ស្វាយ សារឿន មេបញ្ជាការវរសេនាតូចលេខ ៣ តំបន់ប្រតិបត្តិការសឹករង កំពត
៤-អនុសេនីយ៍ឯក សោម យ៉ា មេបញ្ជាការផ្នែកសឹករង កំពត តំបន់ប្រតិបត្តិការសឹករង កំពត
៥-អនុសេនីយ៍ឯក សូ សួរ មេបញ្ជាការផ្នែកសឹករង ជុំគិរី តំបន់ប្រតិបត្តិការសឹករង កំពត
៦-អនុសេនីយ៍ឯក សំ សុខ នាយផ្នែកហ្វឹកហ្វឺន សាលាពលទាហានទី ៣
៧-អនុសេនីយ៍ឯក ឡុង សុខុន នាយការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករង តាកែវ
៨-អនុសេនីយ៍ឯក ឡុង ហេង នាយការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករង តាកែវ
៩-អនុសេនីយ៍ឯក សេក សំ នាយការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករង តាកែវ
១០-អនុសេនីយ៍ឯក សៅ រ៉ុង មេបញ្ជាការវរសេនាតូចលេខ២ តំបន់ប្រតិបត្តិការសឹករងតាកែវ
១១-អនុសេនីយ៍ឯក នួន ហេង មេបញ្ជាការផ្នែកសឹករងជុំគិរី តំបន់ប្រតិបត្តិការសឹករង តាកែវ
១២-អនុសេនីយ៍ឯក កែវ សារឿន មេបញ្ជាការផ្នែកសឹករងព្រាំកក់ តំបន់ប្រតិបត្តិការសឹករង តាកែវ
១៣-អនុសេនីយ៍ឯក ហុង ម៉េងហាក់ មេបញ្ជាការផ្នែកសឹករងព្រៃកប្បាស តំបន់ប្រតិបត្តិការសឹករង តាកែវ
១៤-អនុសេនីយ៍ឯក យ៉ែន ឡេង មេបញ្ជាការផ្នែកសឹករងសំរោង តំបន់ប្រតិបត្តិការសឹករង តាកែវ
១៥-អនុសេនីយ៍ឯក ម៉ែន យ៉ុន នាយការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ
១៦-អនុសេនីយ៍ឯក កោ ឡាយ មេបញ្ជាការផ្នែកសឹករងព្រៃនប់ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ
១៧-អនុសេនីយ៍ឯក ជួប ឡឺយ មេបញ្ជាការផ្នែកសឹករងមិត្តភាព តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ
១៨-អនុសេនីយ៍ឯក នឹម យុន មេបញ្ជាការផ្នែកសឹករងស្ទឹងហាវ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ
១៩-អនុសេនីយ៍ទោ កឹង សេរី នាយគិលានដ្ឋាន តំបន់ប្រតិបត្តិការសឹករង កំពត
២០-អនុសេនីយ៍ទោ កែវ សុផល បញ្ជាការរងវរសេនាតូចលេខ ៣ តំបន់ប្រតិបត្តិការសឹករងកំពត
២១-អនុសេនីយ៍ទោ ឡើ ម៉ុនឈឿន បញ្ជាការរងផ្នែកសឹករងកំពង់ត្រាចតំបន់ប្រតិបត្តិការសឹករងកំពត
២២-អនុសេនីយ៍ទោ មាស សារិទ្ធ បញ្ជាការរងផ្នែកសឹករង ឈូកតំបន់ប្រតិបត្តិការសឹករង កំពត
២៣-អនុសេនីយ៍ទោ ស៊ិន ឃន បញ្ជាការរងផ្នែកសឹករងអង្គរជ័យ តំបន់ប្រតិបត្តិការសឹករងកំពត
២៤-អនុសេនីយ៍ទោ អ៊ុក សំណាង នាយផ្នែកគ្រូយុទ្ធវិធី សាលាពលទាហានទី ៣
២៥-អនុសេនីយ៍ទោ អៀម អឿម គ្រូយុទ្ធវិធី សាលាពលទាហានទី ៣
២៦-អនុសេនីយ៍ទោ សាន គល់ នាយការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករង តាកែវ
២៧-អនុសេនីយ៍ទោ ហ៊ូរ ឆិត នាយការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករងក្រុងព្រះសីហនុ

២៨-អនុសេនីយ៍ឯក ឆេង ឆន នាយរងការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

២៩-អនុសេនីយ៍ត្រី ឃួន សំបូរ មេបញ្ជាការវរសេនាតូចលេខ ១ តំបន់ប្រតិបត្តិការសឹករង ក្រុងព្រះសីហនុ

៣០-អនុសេនីយ៍ត្រី នង វិសាលសក្តិ ជំនួយការការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករង កំពត

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២- សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០

### សារាចរលេខ ០១ សរ

### ស្តីពីការរៀបចំកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ ឆ្នាំលើកទី២ ( ២០០១-២០០៥ )

***

តាំងពីបានបញ្ចប់ជំលសន្និនាខែ វិច្ឆិកា ឆ្នាំ ១៩៩៣ មក រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គមកិច្ច ដើម្បីគោលដៅកាត់បន្ថយភាពក្រីក្រ ។ រាល់សកម្មភាពអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និង សង្គមកិច្ចត្រូវបានដំណើរការដោយមានការធ្វើផែនការការងារជាមុន ដែលរាជរដ្ឋាភិបាលបានកំណត់ថាការងារនេះ គឺជាការគិតគូរពិចារណានិងត្រៀមរៀបចំរាល់លក្ខណៈសម្បត្តិឲ្យទៅជាការចាត់ចែងអនុវត្តជាក់ស្តែង។

តាមហេតុផលខាងលើ និងក្នុងគោលបំណងធានាអោយការអភិវឌ្ឍន៍សេដ្ឋកិច្ច -សង្គមកិច្ចបានប្រព្រឹត្តទៅដោយចីរភាព និងបំរើដោយមានប្រសិទ្ធភាពខ្ពស់នូវទិសដៅនៃការកាត់បន្ថយភាពក្រីក្រ កន្លងមករាជរដ្ឋាភិបាលបានរៀបចំកសាងនិងអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី១ ( ១៩៩៦-២០០០ ) ។

ដើម្បីបន្តអនុវត្តកិច្ចការខាងលើ និងជំរុញផែនការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល អាណត្តិទី២ អោយក្លាយចេញជាយុទ្ធសាស្ត្រដ៏មុះមុត កម្មវិធីការងារ និងគំរោងការងារអនុវត្តជាក់ស្តែង ក្នុងការកសាងប្រទេសជាតិតទៅអនាគត រាជរដ្ឋាភិបាលកំណត់ថា ការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី២ ( ២០០១ ២០០៥ ) គឺជាការងារចាំបាច់ដែលត្រូវតែគិតគូរ ពិចារណារៀបចំឡើងដោយមានចរិតបន្តពីផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំ លើកទី១ ( ១៩៩៦-២០០០ ) ប្រកបទៅដោយវិចារណកម្ម និងមានលក្ខណៈប្រាកដនិយម ។

**I-ការវាយតម្លៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី១ (១៩៩៦-២០០០)**

នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច -សង្គមកិច្ច៥ឆ្នាំលើកទី ១ (១៩៩៦-២០០០) ក្រសួងផែនការបានដើរតួនាទីជាអ្នកសំរបសំរួលកសាងផែនការនេះ ដោយមានការឧបត្ថម្ភជាសំខាន់ពីធនាគារអភិវឌ្ឍន៍អាស៊ី អង្គការសហប្រជាជាតិនៃមូលនិធិសំរាប់កុមារ ព្រមទាំងអង្គការពលកម្មអន្តរជាតិ ។

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី១ (១៩៩៦-២០០០) ត្រូវបានផ្សារភ្ជាប់ជាមួយនឹងកម្មវិធីជាតិសំរាប់នីតិសម្បទានិងអភិវឌ្ឍកម្ពុជានិងផែនការស្តារសេដ្ឋកិច្ច -សង្គមកិច្ចឆ្នាំ១៩៩៤-៩៥ ដែលរដ្ឋសភាបានអនុម័តយល់ព្រមនៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ១៩៩៤ ។ កម្មវិធីជាតិសំរាប់នីតិសម្បទានិងអភិវឌ្ឍកម្ពុជា បានដាក់ចេញនូវទិសដៅរួមនៃកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។ ទិសដៅរួមទាំងនេះ ត្រូវបាន ពង្រីកនិងលំអិតថែមទៀតនៅក្នុងផែនការនេះ ដោយបានបង្កើតក្របខ័ណ្ឌសំរាប់អភិវឌ្ឍន៍ប្រទេសជាតិរយៈពេលមធ្យម មានទាំងទិសដៅម៉ាក្រូសេដ្ឋកិច្ច យុទ្ធសាស្ត្រនិងគោលនយោបាយតាមវិស័យ ដោយមានទំនាក់ទំនងគ្នាទៅវិញទៅមកតាមផ្នែកដែលពាក់ព័ន្ធ ។ ទិសដៅចំបងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់រាជរដ្ឋាភិបាលមាន :

-ការកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍ធនធានមនុស្ស
-កិច្ចអភិវឌ្ឍន៍មូលដ្ឋានផលិតកម្ម
-ការបង្កមុខរបរនិងការងារធ្វើតាមរយៈផ្នែកឯកជន
-ការបង្កើនស្ថិរភាពតួនាទីពីងខ្លួន
-ការពង្រឹងសមត្ថភាពស្រូបយក
-កិច្ចសហប្រតិបត្តិការក្នុងតំបន់ ។

ដើម្បីធ្វើឲ្យសំរេចបាននូវទិសដៅរួមខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់បេកយុទ្ធសាស្ត្រចំបងមួយចំនួនដែលមានចរិតជាយុទ្ធសាស្ត្រអន្តរវិស័យ ដូចមានខាងក្រោម :

-កាត់បន្ថយភាពក្រីក្រតាមរយៈកិច្ចអភិវឌ្ឍន៍ជនបទ ដោយមានការចូលរួមពីសហគមន៍
-លើកទួលាយលទ្ធភាពទទួលសេវាកម្មខាងផ្នែកសង្គមកិច្ច
-កែទំរង់ផ្នែកសាធារណៈ
-លើកកំពស់កិរិតជំនាញ
-អភិវឌ្ឍន៍មូលដ្ឋានផលិតកម្ម ជាពិសេសតាមរយៈការបង្កើនទិន្នផលស្រូវ ជំរុញផលិតកម្មចិញ្ចឹមសត្វ និងធ្វើអោយមានលក្ខណៈសំបូរបែបក្នុងផ្នែកកសិកម្ម ដែលមានលក្ខណៈពាណិជ្ជកម្ម
-ប្រើប្រាស់ប្រភពធនធានអោយមានលក្ខណៈជានិរន្តរភាព
-បង្កមុខរបរតាមរយៈកម្មន្តសាលដើម្បីផលិតទំនិញសំរាប់នាំចេញជំរុញសហគ្រាសទ្រង់ទ្រាយតូចនិងការងារជាឯកត្តជននិងទេសចរណ៍
-ធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ ។

ជារួម ចំណុចខ្លាំងរបស់ផែនការ៥ឆ្នាំលើកទី១នេះ គឺជាឯកសារគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ការអភិវឌ្ឍន៍សង្គមជាតិរបស់រាជរដ្ឋាភិបាល ដែលត្រូវបានយកទៅប្រើប្រាស់ចាប់តាំងពីកំរិតថ្នាក់វិស័យរហូតដល់កំរិតថ្នាក់ជាតិ ដើម្បីតំរែតំរង់ការធ្វើកម្មវិធីវិនិយោគសាធារណៈ សំដៅប្រែក្លាយទិសដៅរួមនៃការអភិវឌ្ឍន៍សង្គមជាតិឲ្យក្លាយទៅជាការអនុវត្តន៍ជាក់ស្តែង ។ តែជាមួយនេះក្នុងការអនុវត្តន៍ផែនការ៥ឆ្នាំលើកទី១នេះ ក៏មានលេចឡើងនូវចំណុចខ្វះខាត ដូចជា :

-ពុំបានកំណត់ក្របខ័ណ្ឌស្ថាប័នអនុវត្តអោយបានច្បាស់លាស់

-ពុំមាននីតិវិធីបទដ្ឋាន និងយន្តការអនុវត្តអោយបានសមស្រប

-គ្មានយន្តការវាយតំលៃ (ប្រចាំឆ្នាំឬពាក់កណ្តាលអាណត្តិ) និងការពិនិត្យតាមដានការអនុវត្តន៍ ដែលជាហេតុនាំអោយយើងពុំអាចធ្វើការកែតំរូវសូចនាករទាំងឡាយដែលបានគ្រោងទុក នៅក្នុងផែនការឲ្យបានទាន់ពេលវេលា និងសមស្របទៅតាមការប្រែប្រួលផ្នែកនយោបាយសេដ្ឋកិច្ច នៅក្នុងប្រទេសក៏ដូចជានៅក្នុងតំបន់ ។ ទន្ទឹមនឹងនេះ យើងពុំមានសូចនាករសំរាប់ពិនិត្យ តាមដានក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ និងគោលនយោបាយតាមផ្នែកនានា

-កង្វះខាតរបាយការណ៍ស្តីពីការអនុវត្តន៍ផែនការរបស់បណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ។

ទាំងចំណុចខ្លាំងនិងចំណុចខ្វះខាតខាងលើនេះ រាជរដ្ឋាភិបាលសន្និដ្ឋានថា ទាំងក្រសួងផែនការផ្ទាល់ដែលជាអ្នកដឹកនាំនិងជាអ្នកសំរបសំរួល ទាំងក្រសួង ស្ថាប័នពាក់ព័ន្ធនានា មានគោលជំហរនិងស្មារតីស្រពិចស្រពិលក្នុងការអនុវត្តន៍ផែនការ៥ឆ្នាំលើកទី១ និងពុំបានដឹងច្បាស់ថា គោលដៅរួមក៏ដូចជាតាមផ្នែករបស់ផែនការត្រូវបានអនុវត្តន៍ដល់ត្រឹមកំរិតណាដែរ ។ ដូច្នេះក្រសួងស្ថាប័ន ខេត្ត ក្រុងទាំងអស់ ចាំបាច់ត្រូវយកចិត្តទុកដាក់កែលំអនៅក្នុងដំណើរការនៃការកសាងផែនការ៥ឆ្នាំលើកទី២ អោយកាន់សមស្របឡើងវិញ ។

## II-ការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច -សង្គមកិច្ច ៥ឆ្នាំលើកទី២ ( ២០០១-២០០៥ )

ខ្លឹមសារនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី២ (២០០១-២០០៥ ) ចាំបាច់ត្រូវអនុលោមតាមស្មារតីនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី២ និងបណ្តាចក្ខុវិស័យជឿនលឿនដែលបានពិចារណាទាន់សភាពការណ៍ទាំងក្នុងប្រទេស ក្នុងតំបន់ និងនៅលើសកលលោក សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចជាតិពីបច្ចុប្បន្នទៅអនាគត ។ ហេតុនេះ គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង នៅពេលចូលរួមកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី២ (២០០១-២០០៥) ត្រូវយកចិត្តទុកដាក់លើគោលដៅ និងយុទ្ធសាស្ត្រជាគន្លឹះ ដូចជា :

-ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងសមធម៌

-ការធានានូវកំណើនសេដ្ឋកិច្ចក្នុងកំរិតមួយខ្ពស់ប្រមាណ ៦%-៧% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេល ២ទៅ៣ទសវត្សរ៍ខាងមុខ ដោយមានការបែងចែកប្រកបទៅដោយសមធម៌នូវផ្លែផ្កា ដែលបានមកពីកំណើនសេដ្ឋកិច្ចនេះ

-ការយកចិត្តទុកដាក់ក្នុងផ្នែកសេដ្ឋកិច្ច ត្រូវបានប្រមូលផ្តុំសំខាន់ទៅលើការធានានូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងដោយមធ្យ័តនូវទ្រព្យ សម្បត្តិសាធារណៈ ការគ្រប់គ្រងនិងប្រើប្រាស់ដោយចិរភាពនូវធនធានធម្មជាតិ ពិសេសធនធានព្រៃឈើ និងការបង្កើនការវិនិយោគសាធារណៈលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងហេដ្ឋារចនាសម្ព័ន្ធសង្គមព្រមទាំងការអភិវឌ្ឍន៍ធនធានមនុស្ស

-កម្ពុជាត្រូវធ្វើការវិនិយោគទុនដោយត់ហុកក្នុងបរិមាណដ៏ច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ដើម្បីអោយសេដ្ឋកិច្ចជាតិប្រមូលបាននូវកំលាំងនិងល្បឿនបានគ្រប់គ្រាន់សំរាប់ការរីកលូតលាស់

-ការរៀបចំនូវបរិស្ថានទូទៅមួយ ដែលមានស្ថេរភាព សន្តិសុខ តម្លាភាព គណនេយ្យភាព និងភាពអាចប៉ាន់ស្មានបាន ដែលអនុគ្រោះនិងជំរុញដល់សកម្មភាពវិនិយោគនៅកម្ពុជា

-ការខិតខំធ្វើការដើម្បីបង្កើនការសន្សំក្នុងស្រុក រួមមានទាំងការសន្សំសាធារណៈ ទាំងការសន្សំរបស់ឯកជន អោយបានព្រមគ្នាទៅនឹងការធ្វើវិចារណកម្មខាងផ្នែកចំណាយ និងកម្មវិធីវិយកម្មចំណូលសាធារណៈ បង្កើនឡើងជាបណ្តើរៗនូវអតិរេកនៃចរិកាចរន្ត ដើម្បីបង្កើតនិងពង្រីកការសន្សំសាធារណៈសំរាប់បំពេញសេចក្តីត្រូវការក្នុងការវិនិយោគសាធារណៈ ពិសេសក្នុងផ្នែកហេដ្ឋានរចនាសម្ព័ន្ធរូបវ័ន្ត និងផ្នែកសង្គមកិច្ច

-ការកសាងសមត្ថភាពស្ថាប័ននិងធានានូវអភិបាលកិច្ចល្អ ដែលជាចំណុចគន្លឹះមួយនៃទស្សនាទានស្តីពីការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌ ដែលជះឥទ្ធិពលដោយផ្ទាល់ទៅលើការកាត់បន្ថយភាពក្រីក្រនិងការបែងចែកនូវផ្លែផ្កានៃកំណើនសេដ្ឋកិច្ច អោយបានជ្រាបសព្វក្នុងគ្រប់ស្រទាប់សង្គមជាតិ

-ការធ្វើសមាហរណកម្មនៃសេដ្ឋកិច្ចជាតិចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

-ការអភិវឌ្ឍន៍ធនធានមនុស្សដោយទាមទារអោយមានការធ្វើវិនិយោគលើធនធានមនុស្ស ជាពិសេសវិនិយោគក្នុងវិស័យអប់រំ និងសុខាភិបាល ដែលជាគន្លឹះនៃការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ ។

## III-ការកំណត់ភារកិច្ចក្នុងការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច -សង្គមកិច្ច៥ឆ្នាំលើកទី២ (២០០១-២០០៥)

ដើម្បីអោយការកសាងផែនការសេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំលើកទី២ (២០០១-២០០៥) បានប្រព្រឹត្តទៅដោយប្រទាក់ក្រឡាគ្នា មានកិច្ចសហការល្អ និងមានការទទួលខុសត្រូវច្បាស់លាស់ រាជរដ្ឋាភិបាលកំណត់ភារកិច្ចដល់បណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ដូចតទៅ :

-ក្រសួងផែនការត្រូវខិតខំទាក់ទងសុំការជួយឧបត្ថម្ភគាំទ្រពី ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក អង្គការពលកម្មអន្តរជាតិ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ អង្គការសហប្រជាជាតិនៃមូលនិធិសំរាប់កុមារ និងអង្គការអន្តរជាតិនានា ដល់ការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី២(២០០១-២០០៥)

-ក្រសួងផែនការត្រូវណែនាំដល់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីវិធីសាស្ត្រក្នុងការវាយតំលៃពីការអនុវត្តន៍ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី១ (១៩៩៦-២០០០) និងអំពីវិធីសាស្ត្រក្នុងការកសាង

ផែនការ៥ឆ្នាំលើកទី២ (២០០១-២០០៥) ដើម្បីឲ្យខ្លឹមសារផែនការអាចឆ្លើយតបបានប្រកបដោយប្រសិទ្ធភាពទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច

-គ្រប់បណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវធ្វើការវាយតំលៃពីការអនុវត្តន៍ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច៥ឆ្នាំលើកទី១ (១៩៩៦-២០០០) និងរៀបចំកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច៥ឆ្នាំលើកទី២ (២០០១-២០០៥) ទៅតាមតួនាទីនិងភារកិច្ចរៀងៗខ្លួន ដោយសហការជាមួយនឹងក្រសួងផែនការ ។

**IV-<u>កាលបរិច្ឆេទនៃការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច -សង្គមកិច្ច៥ឆ្នាំលើកទី២ (២០០១-២០០៥)</u>**

១- មករា- មីនា ឆ្នាំ ២០០០ : ក្រសួងផែនការត្រូវណែនាំឲ្យគ្រប់ស្ថាប័នធ្វើការពិនិត្យវាយតំលៃការអនុវត្តន៍ផែនការ៥ឆ្នាំលើកទី១ និងធងក្រងផែនការ៥ឆ្នាំលើកទី២ក្នុងវិស័យខ្លួនគ្រប់គ្រង ផ្ញើមកក្រសួងផែនការ ។

២- មីនា- មិថុនា ឆ្នាំ ២០០០ : គ្រប់ក្រសួងស្ថាប័នត្រូវផ្ញើឯកសារពិនិត្យវាយតំលៃការអនុវត្តន៍ផែនការ៥ឆ្នាំលើកទី១ និងធងក្រងផែនការ៥ឆ្នាំលើកទី២ ក្នុងវិស័យខ្លួនគ្រប់គ្រង មកក្រសួងផែនការ ។

៣- កក្កដា- សីហា ឆ្នាំ ២០០០ : ក្រសួងផែនការត្រូវសម្របសម្រួល ធងក្រងសេចក្តីព្រាងផែនការ៥ឆ្នាំលើកទី២ ។

៤- កញ្ញា ឆ្នាំ ២០០០ : គណៈរដ្ឋមន្ត្រី ធ្វើការពិនិត្យពិភាក្សាលើសេចក្តីព្រាងផែនការ៥ឆ្នាំលើកទី២ ។

៥- វិច្ឆិកា ឆ្នាំ ២០០០ : គណៈរដ្ឋមន្ត្រី ផ្ញើសេចក្តីព្រាងផែនការ៥ឆ្នាំលើកទី២ ទៅសុំការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា ។

៦- មករា ឆ្នាំ ២០០១ : ក្រសួងផែនការធ្វើការផ្សព្វផ្សាយព្រះរាជក្រម ដែលប្រកាសអោយប្រើច្បាប់ស្តីពីផែនការ៥ឆ្នាំលើកទី២ ដែលអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ។

ទទួលបានសារាចរនេះ រាជរដ្ឋាភិបាលមានជំនឿលើស្មារតីទទួលខុសត្រូវរបស់គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ក្នុងការសហការជាមួយក្រសួងផែនការ ដើម្បីធ្វើការវាយតំលៃពីការអនុវត្តន៍ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំ លើកទី១ (១៩៩៦-២០០០) និងធ្វើការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំលើកទី២ ( ២០០១-២០០៥) ឲ្យទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# III-ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០០០

**ប្រកាសលេខ ៥៥០ អយក.ប្រក**

**ស្ដីពីការពង្រីក និង ប្ដូរឈ្មោះអនុវិទ្យាល័យ " ភ្នំប្រុស "**

**ទៅជាវិទ្យាល័យ " សម្ដេច ជួន ណាត " ស្ថិតនៅក្នុង ឃុំ ក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម**

* * * *

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៨៣ ស្ដីពីការបើកសាលារៀនមធ្យមសិក្សាកំរិត ១ កំរិត ២
- យោងលិខិតស្នើសុំរបស់ សហគមន៍ ឃុំក្រឡា ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយពង្រីក និង ប្ដូរឈ្មោះអនុវិទ្យាល័យ " ភ្នំប្រុស " បច្ចុប្បន្នទៅជា វិទ្យាល័យ " សម្ដេច ជួន ណាត " ចាប់ពីឆ្នាំសិក្សា ១៩៩៩- ២០០០ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និង នាយកវិទ្យាល័យបរសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ឹម សិទ្ធី

★★★

## ២-នីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## ប្រកាស

ភ្នំពេញ,ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០០០

### ប្រកាសលេខ ៤៩ កធស.ប្រក

### ស្តីពីការតែងតាំងមន្ត្រីរាជការ

***

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស/១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងលិខិតលេខ ៤៥ មស.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០០ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងលិខិតលេខ ៤៣៣ ពគរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៩ របស់អភិបាលខេត្ត ពោធិសាត់

- អនុលោមតាមតម្រូវការចាំបាច់របស់ក្រសួង និងសមត្ថភាពរបស់មន្ត្រីរាជការ

**សំរេច**

ប្រការ ១ : តែងតាំងលោក **ឃិន សាមី** បច្ចុប្បន្ននាយការិយាល័យគណនេយ្យសាលាខេត្តពោធិសាត់ ជាអនុប្រធានមន្ទីរធម្មការ និងសាសនាខេត្តពោធិសាត់ ។

ប្រការ ២ : ប្រាក់បៀវត្សរ៍និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **ឃិន សាមី** ចាប់អនុវត្តនៅពេលណាដែលសាលាខេត្តពោធិសាត់ផ្ទេរជូនមន្ទីរធម្មការ និងសាសនាខេត្តពោធិសាត់ ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ( ការិយាល័យបុគ្គលិក- ការិយាល័យគណនេយ្យ ) មន្ទីរធម្មការ និងសាសនាខេត្តពោធិសាត់ និងសាមីខ្លួនត្រូវអនុវត្តរៀងៗ ខ្លួនតាមសេចក្តីប្រកាសនេះ ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

**ជា សាវឿន**

★★★